# របាយការណ៍នៃកិច្ចពិគ្រោះយោបល់ស្តីពី ការបោះឆ្នោត និងប្រជាធិបតេយ្យ

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី
និងយុត្តិធម៌ នៅកម្ពុជា

Committee For Free And Fair Elections In Cambodia

# មាតិកា

**ទំព័រ**


I. **ភាពប្រវត្ត**........................................................................................ 1

II. **ដំណើរការពិគ្រោះយោបល់ និងលទ្ធផល**.................................................... 2

ក. លទ្ធផលនៃការពិគ្រោះយោបល់ទៅលើបញ្ហាកង្វល់ និងបញ្ហាជាអទ្ទិភាព ដែលទាក់ទងទៅនឹងការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា.................................................2

ខ. យោបល់ឬរបៀបនៃការរៀបចំវេទិការស្តីពីកាបោះឆ្នោត និងប្រជាធិបតេយ្យ...........................7

គ. កិច្ចសហប្រតិបត្តការណ៍ជាមួយនិងអ្នកពាក់ព័ន្ធ.............................................................7

III. **ភាពប្រឈម**.......................................................................................8

IV. **អនុសាសន៍**.......................................................................................9

**ឧបសម្ព័ន្ធ**...........................................................................................9

ឧបសម្ព័ន្ធទី១. ការពិគ្រោះយោបល់នៅថ្នាក់ជាតិ..............................................................10

ឧបសម្ព័ន្ធទី២. ការពិគ្រោះយោបល់នៅថ្នាក់ខេត្ត..............................................................15

២.១. ខេត្តបន្ទាយមានជ័យ.................................................................................15

២.២. ខេត្តសៀមរាប........................................................................................21

២.៣. ខេត្តមណ្ឌលគិរី......................................................................................29

២.៤. ខេត្តព្រៃវែង.........................................................................................40

I. កាលប្រវត្ត

ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតតំណាងរាស្ត្រចំនួនបួនដងរួចហើយគឺនៅឆ្នាំ១៩៩៣, ១៩៩៨, ២០០៣ និងឆ្នាំ២០០៨ និងការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនពីរលើកឆ្នាំ២០០២,២០០៧ដែលនេះជាក្តីសង្ឃឹមនៅពេលអនាគតអំពីប្រជាធិបតេយ្យនៅកម្ពុជា បើទោះជាមានបញ្ហានិងការលំបាកមួយចំនួនបានកើតឡើងកំឡុងពេលនៃការបោះឆ្នោតនិមួយៗក៏ដោយ។ នៅពេលមានការបោះឆ្នោតជាតិឆ្នាំ២០០៨ គឺជាសារៈសំខាន់ក្នុងការបង្កើតអោយមានប្រជាធិបតេយ្យ និងពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យតាមរយៈនៃការបើកទូលាយអោយមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងតំណើការបោះឆ្នោត។
តែទោះជាយ៉ាងណាក៏ដោយ បញ្ហាមួយចំនួននៅតែជាបញ្ហាគន្លិះដែលចាំបាច់ត្រូវតែធ្វើការដោះស្រាយ និងកែលំអរបន្ថែមទៀតសម្រាប់ការបោះឆ្នោតនាពេលក្រោយៗមកទៀត។ បញ្ហាទាំងនោះមានដូចជា ប្រព័ន្ធបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយ ការដោះស្រាយបណ្តឹងនៃការបោះឆ្នោត និងសេចក្តីសម្រេចនានា ហិរញ្ញវត្ថុគណបក្សនយោបាយ ការអប់រំអ្នកបោះឆ្នោត ព្រមទាំងបញ្ហាមួយចំនួនទៀតដែលចូលរួមក្នុងការធានាអោយតំណើរការ ប្រជាធិបតេយ្យដូចជា សេរីភាពនៃការបញ្ចេញមតិ សេរីភាពក្នុងការទទួលបានព័ត៌មាន និងសេរីភាពនៃការប្រមូលផ្តុំ។

ដោយមានការគាំទ្រពី UNDP ខុមហ្វ្រែលបានរៀបចំកម្មវិធី និងធ្វើការសិក្សាស្វែងយល់អោយកាន់តែស៊ីជម្រៅថែមទៀតទាក់ទងទៅនឹងបញ្ហាដំណើរការប្រជាធិបតេយ្យ និងការបោះឆ្នោតនៅកម្ពុជាដោយកំណត់អោយច្បាស់លាស់អំពីបញ្ហាទាំងនោះ និងកំណត់អំពីចំណុចដែលគួរកែលម្អ ឬត្រូវកែលម្អដើម្បីធានាថាប្រជាធិបតេយ្យ និងការបោះឆ្នោតនៅកម្ពុជា មានដំណើរការទៅបានដោយតម្លាភាព និងមានលក្ខណៈជាប្រព័ន្ធដែលធានានូវសេរីភាពប្រជាធិបតេយ្យពិតប្រាកដ។

កម្មវិធីស្វែងយលពីដំណើការនៃបញ្ហាដែលកើតមានពាក់ព័ន្ធនឹងការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា នឹងស្វែងរកនូវអនុសាសនសម្រាប់កែលម្អ និងការស្នើរសុំទៅស្ថាប័នដែលពាក់ព័ន្ធ ដោយធ្វើការប្រមូលផ្តុំនូវទស្សនៈយោបល់ពីក្រុមពាក់ព័ន្ធផ្សេងៗគ្នាដែលមានមូលដ្ឋាននៅតាមខេត្ត និងរាជធានីភ្នំពេញ។

ដើម្បីប្រមូលផ្តុំទស្សនៈយោបល់ មតិកែលម្អទៅលើដំណើការបោះឆ្នោត និងប្រជាធិបតេយ្យ ខុមហ្វ្រែលបានរៀបចំក្រុមការងារដើម្បីធ្វើការជួបជុំពិគ្រោះយោបល់ទាំងនៅភ្នំពេញ និងក្នុងខេត្តទាំងបួនគឺ ព្រៃវែង បន្ទាយមានជ័យ សៀមរាប និងមណ្ឌលគីរី។

ក្រុមការងារបានជួបជាមួយតំណាងគណបក្សនយោបាយ តំណាងក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អង្គការសង្គមស៊ីវិល អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដើម្បីធ្វើការពិគ្រោះយោបល់ទៅលើបញ្ហាដែលបានដែលបានកើតឡើងកំឡុងពេលបោះឆ្នោតម្តងៗ និងចំនុចគួកែលំអរ ការពិភាក្សាអំពីកិច្ចសហប្រតិបត្តិការណ៍ទៅលើការរៀប

ចំវេទិការស្តីពីការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា និងក៏ដូចជាវិធីសាស្រ្តក្នុងការរៀបចំវេទិការទាំងនោះ។

របាយការណ៍នេះ បង្ហាញដោយសង្ខេបអំពីកិច្ចពិគ្រោះយោបល់របស់ក្រុមការងារជាមួយអ្នកពាក់ព័ន្ធ។ មតិយោបល់ដែលទទួលបានមកពីការពិគ្រោះយោបល់ត្រូវបានធ្វើការរៀបចំជារួមដើម្បីកំណត់ជាអទិ្ទភាពនៃបញ្ហា ដែលនឹងត្រូវយកទៅពិភាក្សាសម្រាប់ការធ្វើកម្មវិធីវេទិការនៅតាមបណ្តាខេត្តនិមួយៗ និងការប្រមូលផ្តុំអនុសាសន៍កែលំអរទាំងនោះសម្រាប់ដាក់ចូលទៅក្នុងការពិភាក្សារួមនៅក្នុង មណ្ឌលនិមួយៗសម្រាប់កំឡុងពេលធ្វើវេទិការ។

## II. ដំណើរការពិគ្រោះយោបល់ និងលទ្ធផល

ក្រុមការងារខុមហ្វ្រែលបានរៀបចំដំណើរការពិគ្រោះយោបល់ដែលបានរៀបចំជាពីរប្រភេទ គឺ ការពិគ្រោះយោបល់ថ្នាក់ជាតិដែលធ្វើនៅភ្នំពេញ និងការពិគ្រោះយោបល់ថ្នាក់ខេត្តចំនួនបួននៅទូរទាំងប្រទេស។

ការពិគ្រោះយោបល់នេះមានរយៈពេលមួយសប្តាហ៍ដែលចាប់ផ្តើមពីថ្ងៃទី២៧ ខែសីហា រហូតដល់ថ្ងៃទី១៥ ខែកញ្ញានៅតាមខេត្តចំនួនបួន គឺខេត្ត ព្រៃវែង បន្ទាយមានជ័យ មណ្ឌលគីរី និងខេត្តសៀមរៀប និងរាជធានីភ្នំពេញ។ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនេះគឺមានគោលដៅសំខាន់គឺះ

- ជជែកពិភាក្សាអំពីបញ្ហា កង្វល់ និងបញ្ហាជាអទិ្ទភាពដែលទាក់ទងទៅនឹងការបោះឆ្នោត និងប្រជាធិបតេយ្យ។
- ជជែកពិភាក្សា និងផ្លាស់ប្តូរយោបល់ពីរបៀបរៀបចំវេទិការបោះឆ្នោត និងប្រជាធិបតេយ្យ។
- ស្វែងរកកិច្ចសហប្រតិបត្តការពីអ្នកពាក់ព័ន្ធក្នុងការរៀបចំវេទិការស្តីពីការបោះឆ្នោត និងប្រជាធិបតេយ្យ។

ក្រុមដែលបានធ្វើការពិគ្រោះយោបល់នោះរួមមានតំណាងគណបក្ស នយោបាយទាំងប្រាំដែលមានអសនៈនៅក្នុងរដ្ឋសភា គណៈកម្មការខេត្តរៀបចំការបោះឆ្នោត អតីតគណៈកម្មការឃុំរៀបចំការបោះឆ្នោត ស្មៀនឃុំ ក្រុមប្រឹក្សាខេត្ត ក្រុង អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ទាក់ទងពីបញ្ហាការបោះឆ្នោត និងប្រជាធិបតេយ្យ។

### ក. លទ្ធផលនៃការពិគ្រោះយោបល់ទៅលើបញ្ហាកង្វល់ និងបញ្ហាជាអទិ្ទភាពដែលទាក់ទងទៅនឹងការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា

## ប្រព័ន្ធបោះឆ្នោត

ប្រព័ន្ធបោះឆ្នោតដែលបាននិងកំពុងប្រើប្រាស់នៅពេលបច្ចុប្បន្ននេះ មានការគាំទ្រពីសំណាក់គណបក្សនយោបាយភាគច្រើន ក៏ប៉ុន្តែចំពោះរូបមន្តនៃការបែងចែងអសនៈគឺមានគណបក្សជាច្រើនចង់អោយផ្លាស់ប្តូរ ពីព្រោះរូបមន្តដែលបែងចែងអសនៈនៅពេលបច្ចុប្បន្ននេះ គឺមិនមានភាពយុត្តិធ៌មសម្រាប់គណបក្សតូចៗ ចំណែកឯបេក្ខជនដែលជាប់ឆ្នោតមិនបានទទួលខុសត្រូវចំពោះម្ចាស់ឆ្នោតនៅតាមមណ្ឌលទេ គឺត្រូវទទួលខុសត្រូវចំពោះបក្សនយោបាយរបស់ខ្លួនវិញ។

គណបក្សភាគច្រើនចង់ប្រើប្រាស់រូបមន្តបែងចែកដូចសម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយអ៊ុនតាក់ (UNTAC) ដែលប្រើប្រាស់រូបមន្តសំណល់ធំ ហើយគាំទ្រអោយគណបក្សនយោបាយនិមួយៗបញ្ចូលកូតាស្ត្រីអោយបានយ៉ាងតិចណាស់ ៣០% នៅក្នុងបញ្ជីបេក្ខជនរបស់ខ្លួន។សម្រាប់ការប្រើប្រាស់ប្រព័ន្ធបោះឆ្នោត កម្ពុជាគួតែងាកមកពិចារណានូវការប្រើប្រាស់ប្រព័ន្ធបោះឆ្នោតចំរុះមួយដែលមានទាំងការបោះឆ្នោតអោយទៅគណបក្សនយោបាយ និងការបោះឆ្នោតអោយបេក្ខជនឯករាជ្យ។

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

គណបក្សនយោបាយមួយចំនួនយល់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនបានរក្សាគោលការណ៍អព្យាក្រិត្យ និងត្រូវបានគេមើលឃើញថាមានភាពលម្អៀងទៅរកគណបក្សកាន់អំណាច។ មានមន្ត្រី គ.ជ.ប ជាច្រើនខ្វះសមត្ថភាពក្នុងការបំពេញកិច្ចការរបស់ខ្លួនទាក់ទងទៅនឹងការរៀបចំការបោះឆ្នោត មិនមានតម្លាភាពក្នុងការជ្រើសរើសមន្ត្រី គ.ជ.ប នៅថ្នាក់តំបន់។

មានការសំណូមពរស្មើតែគ្រប់គណបក្សនយោបាយ និងអ្នកពាក់ព័ន្ធទាំងអស់ថា ស្ថាប័ន គ.ជ.ប គឺតែត្រូវតែចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ដើម្បីអោយស្ថាប័ននេះ មានអំណាច និងឯករាជ្យភាពគ្រប់គ្រាន់នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ចំណែកឯសមាសភាពវិញ គឺត្រូវអោយមានតំណាងគ្រប់គណបក្សនយោបាយដែលមានអសនៈនៅក្នុងរដ្ឋសភា សមាសភាពនេះត្រូវមាននៅគ្រប់ជាន់ថ្នាក់នៃ គ.ជ.ប ទាំងអស់។ ជាជម្រើសមួយទៀតដែរសម្រាប់សមាសភាព គ.ជ.ប គឺគួតែមានកាចូលរួមជាមួយនិងអង្គការសង្គមស៊ីវិលដែលដែលធ្វើការពាក់ព័ន្ធនៅក្នុងរឿងបោះឆ្នោត។

## ការចុះឈ្មោះអ្នកបោះឆ្នោតនិងបញ្ជីឈ្មោះអ្នកបោះឆ្នោត

គណបក្សនយោបាយភាគច្រើនបានលើកឡើងថា បញ្ជីឈ្មោះបោះឆ្នោតនៅពេលបច្ចុប្បន្ននៅតែមានបញ្ហាច្រើន ជាពិសេសបញ្ហា ឈ្មោះស្ទួន និងការលប់ឈ្មោះដោយមិនមានឯកសារបញ្ជាក់ច្បាស់លាស់មុនពេលលប់ឈ្មោះ។ ការធ្វើប្រតិភូកម្មអំណាចអោយទៅស្មៀនឃុំសង្កាត់ជាអ្នកចុះឈ្មោះបោះឆ្នោតជាបញ្ហា ពីព្រោះអ្នកទាំងនោះជាមន្ត្រីរបស់គណបក្សនយោបាយដែលមិនអាចរក្សាគោលជំហរអព្យាក្រិត្យបានសម្រាប់អ្នកចុះឈ្មោះបោះឆ្នោតទាំងឡាយណាដែលមាននិន្នាការនយោបាយផ្សេងពីគាត់។

មតិភាគច្រើននៃអ្នកពាក់ព័ន្ធបានលើកឡើងថា រយៈពេលនៃការចុះឈ្មោះបោះឆ្នោតគួរតែមានរយៈពេលវែងជាងពេលដែលត្រូវបានកំណត់ដោយច្បាប់ពេលបច្ចុប្បន្ន។ គ.ជ.ប គួរតែធ្វើការងារចុះឈ្មោះបោះឆ្នោតវិញ។ បញ្ជីឈ្មោះបោះឆ្នោតត្រូវតែបានធ្វើសវនកម្មអោយបានញឹកញាប់ និងត្រូវមានឯកសាច្បាស់លាស់ និងគ្រប់គ្រាន់សម្រាប់លប់ឈ្មោះ។ ចំពោះការប្រើប្រាស់នូវទម្រង់ ១០១៨ វិញប្រសិនជាអាច ត្រូវរកវិធីផ្សេងមកជំនួសវិញ ឬប្រើទម្រង់នេះដដែល តែត្រូវតែមានវិធានការច្បាស់លាស់ក្នុងការគ្រប់គ្រងអំពីការចេញអោយប្រើនូវទម្រង់១០១៨នេះ។ ពង្រឹងសមត្ថភាពបន្ថែមចំពោះមន្ត្រីរៀបចំការបោះឆ្នោត ជាពិសេសមន្ត្រីថ្នាក់តាមតំបន់អំពីនីតិវិធី និងច្បាប់បោះឆ្នោត។

### ប្រព័ន្ធផ្សព្វផ្សាយ

មានការលើកឡើងស្ទើតែទាំងអស់ជាមួយនិងក្រុមដែលត្រូវបានពិភាក្សាពិគ្រោះយោបល់ ថាប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋស្ថិតនៅក្រោមគណបក្សកាន់អំណាច។ ការចាក់ផ្សាយមានភាពលម្អៀងទៅរកគណបក្សកាន់អំណាច មិនមានតុល្យភាពក្នុងការចាក់ផ្សាយនូវរាល់ព័ត៌មានដែលមាននិន្នាការប្រឆាំង ឬរិះគន់រដ្ឋាភិបាល។

គួតែមានការបង្កើតនូវគណៈកម្មការដើម្បីគ្រប់គ្រងការចាក់ផ្សាយ ដើម្បីធានានូវតុល្យភាព និងតម្លាភាពនៃគ្រប់ព័ត៌មាន និងធ្វើការបែងចែកម៉ោងផ្សព្វផ្សាយអោយបានស្មើៗគ្នា និងមានការផ្តន្ទាទោសចំពោះប្រព័ន្ធផ្សព្វផ្សាយណាដែលមិនគោរពច្បាប់។ អង្គការសង្គមស៊ីវិលគួតែបង្កើតប្រព័ន្ធផ្សព្វផ្សាយមួយចាក់ផ្សាយនូវគ្រប់ព័ត៌មានទាំងអស់ជូនទៅដល់សាធារណៈជន។

### ការដោះស្រាយបណ្តឹងនៃការបោះឆ្នោតនិងសេចក្តីសម្រេច

ការដោះស្រាយបណ្តឹងទាក់ទងទៅនឹងការបោះឆ្នោតនៅតែមានភាពមិនច្បាស់លាស់ ដែលទាក់ទងទៅនឹងសមត្ថភាពនៃមន្ត្រីដែលទទួលបន្ទុកដោះស្រាយបណ្តឹង បណ្តឹងភាគច្រើនត្រូវបានសម្របសម្រួលច្រើនជាងការអនុវត្តច្បាប់។

គួបង្កើតនូវយុត្តាធិការដាច់ដោយឡែកមួយសម្រាប់ដោះស្រាយបណ្តឹងទាក់ទងទៅនឹងបទល្មើសនៃការបោះឆ្នោត និងការរៀបចំការបោះឆ្នោត។

### ហិរញ្ញវត្ថុនយោបាយ

មានការយល់ស្របជាឯកច្ឆ័នពីអ្នកដែលត្រូវបានពិភាក្សាពិគ្រោះយោបល់ថា ការប្រើប្រាស់ហិរញ្ញវត្ថុរបស់គណបក្សនយោបាយមិនមានតម្លាភាព ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតមិនអាចដឹងថាតើគណបក្សនយោបាយនិមួយៗបានថវិការមកពីណាខ្លះ និងយកទៅធ្វើអ្វីខ្លះ ដែលដើមហេតុដែលនាំអោយមានអំពើពុករលួយ ហើយក៏អាចអោយមានការខ្វះទំនុកចិត្តមកលើគណបក្សនយោបាយ។

មតិភាគច្រើនគាំទ្រអោយមានច្បាប់សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយ ដើម្បីអោយអ្នកបោះឆ្នោតបានដឹងអំពីការប្រើប្រាស់លុយនៃគណបក្សនយោបាយនិមួយៗ និងលើក

កំពស់តម្លាភាព កាទុកចិត្តទៅលើការដឹកនាំប្រទេសនៃគណបក្សដែលបានជាប់ឆ្នោតពីសំណាក់អ្នកបោះឆ្នោត។ គួរតែមានដែនកំណត់ទៅលើការចំណាយថវិការនៃណគបក្សនយោបាយពេលធ្វើការឃោសនាបោះឆ្នោតដើម្បី អោយមានភាពយុត្តិធ៌មក្នុងការស្វែងរកឳកាស់ទទួលបានសន្លឹកឆ្នោតពីអ្នកបោះឆ្នោត និងរក្សាតុល្យភាពរវាងគណបក្សដែលមានធនធានច្រើន និងមិនសូវមានធន់ជាន។

**ការអប់រំអ្នកបោះឆ្នោត**

ការអប់រំអ្នកបោះឆ្នោតនៅតែជាបញ្ហាធំសម្រាប់ប្រជាពលរដ្ឋ ជាពិសេសនៅតាមតំបន់ដាច់ស្រយាល និងតំបនដែលមានជនជនភាគតិចរស់នៅ។ មានប្រជាពលរដ្ឋជាច្រើននូវមិនទាន់យល់អំពីការបោះឆ្នោត និងនីតិវិធីបោះឆ្នោត។

ការអប់រំអ្នកបោះឆ្នោតត្រូវតែធ្វើអោយបានជាប្រចាំ ជាពិសេសដល់ជនជាតិភាគតិច និងតំបន់ដាច់ស្រយាល ដោយប្រើប្រាស់ភាសា និងតួសម្តែងជារបស់ជនជាតិភាគតិច។ អង្គការសង្គមស៊ីវិលគួរតែជួយក្នុងការអប់រំអ្នកបោះឆ្នោត។

**សេរីភាពក្នុងការបញ្ចេញមតិ**

ការបញ្ចេញមតិនៅមានកំរិត និងការខ្លបខ្លាចនៅឡើយ ជាពិសេសការបញ្ចេញមតិប្រឆាំងទៅនឹងគណបក្សកាន់អំណាច សមាជិកសភាគណបក្សប្រឆាំងតែងតែប្រឈមមុខនឹងបណ្តឹងបរិហាកេរ្តិ៍ទាក់ទងទៅនឹងការបញ្ចេញមតិរបស់ពួកគេ។ ច្បាប់មិនបានកំណត់ន័យអោយបានច្បាស់លាស់ទាក់ទងទៅនឹងបទល្មើសបរិហាកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត។

កំណត់និយមន័យអោយបានច្បាស់លាស់ទាក់ទងទៅនឹងច្បាប់ស្តីពីការបរិហាកេរ្តិ៍ និងការផ្សាយនូវព័ត៌មានមិនពិត។ ត្រូវធានាថារាល់ការបញ្ចេញមតិរិះគន់ក្នុងន័យកែលម្អត្រូវបានចាក់ផ្សាយ និងមិនមានការបំភិតភ័យ។

**សិទ្ធិនៃការទទួលព័តមាន**

ការទទួលបាននូវព័ត៌មានសាធារណៈនូវមានកម្រិតនៅឡើយជាពិសេសទាក់ទងទៅនឹង ការអភិវឌ្ឍន៍ផ្សេងៗ ដែលទាក់ទងជាមួយនឹងប្រជាពលរដ្ឋ បើទោះបីជាចង់ស្វែងរកព័ត៌មានក៏មានការលំបាក។

រដ្ឋាភិបាលគួរផ្តល់អទិភាពទីមួយនៃការអនុម័តច្បាប់ស្តីពីការទទួលបាននូវព័ត៌មានសាធារណៈ ។ ត្រូវតែបង្ករអោយមានភាពងាយស្រួលជូនទៅសាធារណៈជនក្នុងការស្វែងរកនូវព័ត៌មានពីស្ថាប័នរដ្ឋ។

**សេរីភាពនៃការប្រមូលផ្តុំ**

សិទ្ធិនៃការប្រមូលផ្តុំនៅមានកម្រិតនៅឡើយ បើទោះជាច្បាប់ធានានូវការអនុវត្តសិទ្ធិនេះក៏ដោយ។ អាជ្ញាធរតែងតែបំភិតបំភ័យប្រជាពលរដ្ឋក្នុងការប្រមូលផ្តុំគ្នា ដោយអោយសុំច្បាប់អនុញ្ញាតិជាមុនសិនពីអាជ្ញាធរមានសមត្ថកិច្ច ឬក៏យកលេសថាប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

គួរតែលប់បំបាត់ការសុំអនុញ្ញាតច្បាប់ ដោយត្រឹមតែជូនជាតំណឹងជាមុន និងអាជ្ញាធរត្រូវតែរក្សាសុវត្ថិភាព និងសន្តិសុខជូនប្រជាពលរដ្ឋដែលធ្វើការប្រមូលផ្តុំគ្នា។

**បញ្ហាអទិ្ទភាពដែលខេត្តនិមួយៗបានលើកឡើង**

| បញ្ហាដែលបានលើកឡើង | មណ្ឌល | | | |
|---|---|---|---|---|
| | ព្រៃវែង | បន្ទាយមានជ័យ | មណ្ឌលគីរី | សៀមរាប |
| បញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត | ✓ | ✓ | ✓ | ✓ |
| សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ✓ | ✓ | | ✓ |
| ប្រព័ន្ធបោះឆ្នោត | | | ✓ | ✓ |
| ប្រព័ន្ធផ្សព្វផ្សាយ | ✓ | | | |
| ការអប់រំអ្នកបោះឆ្នោត | | | ✓ | |
| ហិរញ្ញវត្ថុគណបក្សនយោបាយ | | ✓ | | |
| ការដោះស្រាយបណ្តឹងបោះឆ្នោត | | | | |
| សេរីភាពបញ្ចេញមតិ | ✓ | ✓ | ✓ | ✓ |
| សេរីភាពនៃការប្រមូលផ្តុំ | ✓ | ✓ | | ✓ |
| សេរីភាពនៃការទទួលបានព័ត៌មាន | | | ✓ | |

ផ្អែកទៅលើតារាងខាងលើដែលទទួលបានពីការពិគ្រោះយោបល់ យើងឃើញថាបញ្ហាជាអទិ្ទភាពទាំងប្រាំរបស់មណ្ឌលនិមួយៗមានដូចតទៅ៖

- **ខេត្តបន្ទាយមានជ័យ៖** បញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត សមាសភាពគណកម្មាធិការជាតិរៀបចំការបោះឆ្នោត ហិរញ្ញវត្ថុគណបក្សនយោបាយសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការប្រមូលផ្តុំ។
- **ខេត្តព្រៃវែង៖** បញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយ សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការប្រមូលផ្តុំ។
- **ខេត្តសៀមរាប៖** បញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រព័ន្ធបោះឆ្នោត សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការប្រមូលផ្តុំ។

- **ខេត្តមណ្ឌលគីរី៖**បញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ប្រព័ន្ធបោះឆ្នោតការអប់រំអ្នកបោះឆ្នោត សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពទទួលបានព័ត៌មាន។

**ខ. យោបល់ ឬរបៀបនៃការរៀបចំវេទិការស្តីពីការបោះឆ្នោត និងប្រជាធិបតេយ្យ**

ក្រុមការងារបានធ្វើការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ ព្រមទាំងបង្ហាញនូវគំរូអំពីរបៀបរៀបចំវេទិការដូចជា វេទិការនិមួយៗត្រូវបានចែកចេញជាបួនវគ្គគឺ៖

វគ្គទីមួយនៅពេលបើកអង្គវេទិការ មានការធ្វើបទបង្ហាញពីវាគ្មិនជំនាញ ទាក់ទងទៅនឹងការបោះឆ្នោតនិងលំហប្រជាធិបតេយ្យនៅក្នុងវគ្គទីមួយ។ វគ្គទីពីរគឺមានការបែងចែងអ្នកចូលរួមទាំងអស់ជាប្រាំក្រុម ដែលនៅក្នុងមួយក្រុមៗ មានសមាជិកយ៉ាងតិចចំនួនម្ភៃនាក់សម្រាប់ប្រធានបទមួយ។ នៅក្នុងក្រុមនិមួយៗមានវាគ្មិនតំណាងក្រុម អ្នកសម្របសម្រួល និងអ្នកកត់ត្រា។ ក្រុមនិមួយៗត្រូវពិភាក្សានិងផ្តល់នូវអនុសាសន៍ទៅលើបញ្ហាដែលបានជាប់ជាអទិភាពប្រចាំខេត្តរបស់ខ្លួន ពេលពិភាក្សារកបាននូវអនុសាសន៍ អ្នកសម្របសម្រួលក្រុមត្រូវធ្វើយ៉ាងណាអោយមានការឯកភាពយល់ព្រមពីសមាជិករបស់ក្រុមដើម្បីយកទៅបង្ហាញនៅក្នុងអង្គវេទិការទាំងមូល។ វគ្គទីបីគឺកាបង្ហាញអនុសាសន៍របស់ក្រុមនិមួយៗជូនវេទិការទាំងមូល និងការពិភាក្សាពេញអង្គរវាងវាគ្មិនតំណាងក្រុម វាគ្មិនជំនាញ និងវាគ្មិនតំណាងអោយគណបក្សនយោបាយ និងការសួរសំនួរពីអ្នកចូលរួមទាំងអស់ទាក់ទងទៅនឹងបញ្ហានិមួយៗ ទៅកាន់វាគ្មិននៅក្នុងការពិភាក្សាពេញអង្គដើម្បីធ្វើការរកអនុសាសន៍ជារួមទៅលើបញ្ហានិមួយៗប្រចាំខេត្ត។ វគ្គទីបួន គឺការបោះឆ្នោតគាំទ្រពីអ្នកចូលរួមនៅក្នុងវេទិការទាំងអស់ទៅលើអនុសាសន៍នៃបញ្ហានិមួយៗ ដែលការបោះឆ្នោតនោះមានជម្រើសបី គឺ គាំទ្រ មិនគាំទ្រ និងអនុប្បវាទ។ បន្ទាប់ពីការបោះឆ្នោតត្រូវបានបញ្ចប់រួចហើយ អនុសាសន៍ទាំងអស់នោះនឹងត្រូវបានបោះពុម្ពចែកអ្នកចូលរួមនៅក្នុងអង្គវេទិការទាំងអស់មុនពេលបិទវេទិការ។

ក្នុងកំឡុងពេលជជែកពិភាក្សា ក្រុមការងារទាំងថ្នាក់ជាតិ និងថ្នាក់ខេត្តបានពន្យល់ជូនទៅអ្នកពិគ្រោះយោបល់ដែលពាក់ព័ន្ធទាំងអស់អំពីពង្រៀងនៃការរៀបចំ និងដំណាក់កាលទាំងនេះនៅក្នុងវេទិការតាមខេត្តនិមួយៗ។ដោយផ្អែកទៅលើការពិគ្រោះយោបល់ ក្រុមអ្នកពាក់ព័ន្ធទាំងអស់បានស្នើរជាយោបល់មួយចំនួនដូចជា៖

- ភាគច្រើននៃអ្នកពាក់ព័ន្ធបានឯកភាពថា វេទិការគួរតែមានវាគ្មិនជំនាញធ្វើការបង្ហាញទាក់ទងទៅនឹងបញ្ហាដែលបានរកឃើញក្នុងកំឡុងពេលពិគ្រោះយោបល់។
- វាជាពេលវេលាល្អដែលវេទិការគួរមានក្រុមពិភាក្សាតូចៗ និងក្រុមធំ។ក្រុមតូចៗនិមួយៗគួរមានវាគ្មិនមួយរូប អ្នកសម្របសម្រួលមួយរូប និងអ្នកកត់ត្រាមួយរូប។
- គួមានការពិភាក្សាសម្រាប់ក្រុមធំ និងវាគ្មិន គួរបញ្ចូលតំណាងរាស្ត្រតំណាងក្រសួងមហាផ្ទៃសង្គមស៊ីវិល ក៏ដូចជាអ្នករាយការណ៍ពីក្រុមពិភាក្សាតូចៗ។

- សមាជិកសភាគួរចូលរួមនៅក្នុងវេទិការបែបនេះ ពីព្រោះពួកគេមានអំណាចដែលមានឥទ្ធិពលដល់ការធ្វើសេចក្តីសម្រេចចិត្ត។
- អ្នកចូលរួមនៅក្នុងវេទិការគួរតែអ្នកដែលពាក់ព័ន្ធទៅលើបញ្ហាដែលនឹងលើកយកមកជជែកពិភាក្សានៅក្នុងវេទិការ។
- ក្រុមពិភាក្សាគួរបែងចែករវាងអ្នកចូលរួមធម្មតា និងអជ្ញាធរមូលដ្ឋានដែលធ្វើអោយពួកគេមានសេរីភាពក្នុងការនិយាយ ឬជជែកពិភាក្សា។
- វេទិការមិនគួររៀបចំឡើងកំឡុងពេលនៃការចុះឈ្មោះបោះឆ្នោតទេ ដើម្បីអោយស្មៀនមានឱកាស់បានចូលរួមក្នុងវេទិការអោយបានពេញលេញ។

**គ. កិច្ចសហប្រតិបត្តការណ៍ជាមួយនិងអ្នកពាក់ព័ន្ធ**

កំឡុងពេលពិគ្រោះយោបល់ ក្រុមការងារបានរៀបចំសំនួរខ្លះដើម្បីពិនិត្យមើលទៅលើការប្តេជ្ញាចិត្តក្នុងការចូលរួម ក៏ដូចជាគំនិតនៃការចូលរួមសកម្មពីគ្រប់ក្រុមអ្នកពាក់ព័ន្ធដូចជា ក្រុមមកពីគណបក្សនយោបាយ គណៈកម្មការខេត្ត/ក្រុង រៀបចំការបោះឆ្នោត គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត ក្រុមប្រឹក្សាខេត្ត សង្គមស៊ីវិល និងស្មៀនឃុំ សង្កាត់។ចំពោះកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ ក្រុមការងារក៏បានសួរ និងស្វែងរកកិច្ចសហប្រត្តិបត្តការណ៍ជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រសួងមហាផ្ទៃ សមាជិកសភា និងគណបក្សនយោបាយនៅថ្នាក់ជាតិ។ ជាលទ្ធផលអ្នកពាក់ព័ន្ធមួយចំនួនធំមានការចាប់អារម្មណ៍ទៅលើសកម្មភាព និងសន្យាថានឹងចូលរួមក្នុងដំណើរការនៃវេទិការនៅពេលណាដែលពួកគេបានទទួលការអញ្ជើញអោយចូលរួម និងមានរបៀបវារៈសម្រាប់វេទិការ។
នៅក្នុងកំឡុងពេលពិភាក្សា ឯកឧត្តម ជាម យាប បានស្នើរអោយខុមហ្វ្រែលរៀបចំវេទិការប្រហាក់ប្រហែលនេះនៅក្នុងអាគាររដ្ឋសភា ដើម្បីជជែកពិភាក្សាបញ្ហាដែលទាក់ទងទៅនឹងការបោះឆ្នោតនិងប្រជាធិបតេយ្យ។ ឯកឧត្តមក៏បានស្នើរអោយអញ្ជើញតំណាងរាស្ត្រមកពីគ្រប់គណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចូលរួមជជែកនៅក្នុងវេទិការនេះផងដែរ។

ជារួមការស្នើសុំ កិច្ចសហប្រតិបត្តិការណ៍ពីក្រុមពាក់ព័ន្ធដែលបានពិភាក្សានិមួយៗ គឺបានទទួលការសហការណ៍យ៉ាងល្អប្រសើរ និងត្រៀមជានិច្ចចំពោះការការសហការណ៍ផ្សេងៗទៀតនៅពេលអនាគត។

## III. ភាពប្រឈម

នៅក្នុងដំណើការធ្វើការពិគ្រោះយោបល់នេះ មានបញ្ហាប្រឈមខ្លះៗដូចជា ពេលវេលាដែលផ្តល់អោយសម្រាប់អ្នកដែលចុះទៅធ្វើការពិភាក្សាជាមួយនិងក្រុមនិមួយៗ និងពេលវេលាដែលផ្តល់អោយសម្រាប់លេខាខុមហ្វ្រែលខេត្តក្នុងការធ្វើការណាត់សុំជួបពិភាក្សា ជាមួយនឹងក្រុមពាក់ព័ន្ធនិមួយៗ មិនគ្រប់គ្រាន់។ ភាគច្រើននៃក្រុមពាក់ព័ន្ធដែលបានពិភាក្សានិមួយៗនៅតាម

តំបន់មានការយល់ដឹងតិចតួច និងមិនហ៊ានបញ្ចេញមតិ ឬមិនមានការយល់ដឹងតែម្តងចំពោះសំនួរខ្លះៗ ដែលធ្វើអោយមានការពិបាកក្នុងការសុំជាយោបល់ ឬអនុសាសន៍មកវិញពីក្រុមទាំងនោះ បើទោះបីជាមានការពន្យល់ពីក្រុមការងារក៏ដោយ។

## IV. **អនុសាសន៍**

- គួរតែមួយថ្ងៃជួបតែពីរក្រុមដើម្បីអោយមានពេលវេលាគ្រប់គ្រាន់ក្នុងការជួបពិភាក្សាជាមួយក្រុមនិមួយៗ និងមិនមានការយឺតពេលក្នុងការទៅជួបក្រុមមួយទៀត។
- គួរតែផ្តល់ពេលវេលាទៅអោយលេខាខេត្តអោយបានគ្រប់គ្រាន់ក្នុងការដាក់លិខិត្តសុំជួបជាមួយក្រុមដែលត្រូវជួបពិភាក្សា។
- សំនួរដែលត្រៀមសម្រាប់ក្រុមពិភាក្សានិមួយៗ គួរតែត្រូវបានបែងចែកអោយបានត្រឹមត្រូវ និងសមស្របទៅតាមសមត្ថភាព និងការងារនៃក្រុមពិភាក្សានិមួយៗ។
- គួរតែមានការរៀបចំនៅក្នុងរដូវដែលមិនមានភ្លៀងដែលអាចជួយសម្រួលដល់ការងារជួបប្រជុំ និងមិនចំពេលចុះឈ្មោះអ្នកបោះឆ្នោតដែលងាយស្រួលក្នុងការជួបជាមួយស្មៀនឃុំ សង្កាត់។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១. ការពិគ្រោះយោបល់នៅថ្នាក់ជាតិ

### គណបក្សប្រជាជនកម្ពុជា





គណៈប្រតិភូនៃគណបក្សប្រជាជនកម្ពុជាបានចាប់អារម្មណ៍ទៅលើបញ្ហាប្រជាធិបតេយ្យនៅកម្ពុជា ភាពគំលាតគ្នារវាងអ្នកចេះ និងអ្នកមិនចេះ គឺធ្វើយ៉ាងណាអោយបញ្ហាប្រជាធិបតេយ្យបានទៅដល់ប្រជាពលរដ្ឋតាមរយៈនៃការផ្តល់នៃការយល់ដឹងអំពីច្បាប់នានាដល់ពលរដ្ឋនៅតាមមូលដ្ឋាន។ពាក់ព័ន្ធទៅនឹងការងារបោះឆ្នោត គណៈប្រតិភូបានមានប្រសាសន៍ថា ពុំទាន់មានភាពសុក្រិត្យមួយរយភាគរយនៅឡើយទេ ត្រូវធ្វើយ៉ាងណាអោយអ្នកពាក់ព័ន្ធមានការយល់ដឹងអំពីច្បាប់ ពិសេស ច្បាប់បោះឆ្នោត ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់គណបក្សនយោបាយ និងអំពីស្ថាប័ននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាដើម។ ដោយត្រូវធ្វើយ៉ាងណាអោយអ្នកពាក់ព័ន្ធទាំងអស់មានការគោរពទៅតាមអ្វីដែលច្បាប់បានកំណត់។គណៈប្រតិភូបានស្នើរអោយមានការចូលរួមពីសំណាក់អ្នកសង្កេតការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងដំណើរការសង្កេតការណ៍បោះឆ្នោតដោយធ្វើយ៉ាងណាអោយការបោះឆ្នោតមានការកំណត់យកនូវនិយាមមួយច្បាស់លាស់ ដែលអាចទទួលយកបានទាំងអស់គ្នា។

ពាក់ព័ន្ធទៅលើកិច្ចសហប្រតិបត្តការណ៍ក្នុងការរៀបចំវេទិកានៅតាមខេត្ត គណៈប្រតិភូបានសម្តែងការគាំទ្ររទៅលើសកម្មភាពនេះ មិនតែប៉ុណ្ណោះគណៈប្រតិភូ ថែមទាំងស្នើអោយមានការរៀបចំជាវេទិកានៅក្នុងអគាររដ្ឋសភា ដោយធ្វើយ៉ាងណាអោយមានការចូលរួមពីគ្រប់គណបក្សទាំងអស់ និងពីស្ថាប័នដែលពាក់ព័ន្ធក្នុងការបោះឆ្នោតដូចជា ក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាដើម ដើម្បីធ្វើការជជែកអោយបានស៊ីជម្រៅក្នុងការកែលម្អច្បាប់ពាក់ព័ន្ធការបោះឆ្នោតនៅប្រទេសកម្ពុជា។

### គណបក្សសមរង្ស៊ី

នៅក្នុងកិច្ចពិភាក្សាពិគ្រោះយោបល់នោះគណប្រតិភូនៃគណបក្សសមរង្ស៊ីចង់អោយមានការ កែប្រែច្បាប់ពីរគឺច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីគណបក្សនយោ

បាយ ។ ទាក់ទងទៅនឹងច្បាប់ស្តីពីគណបក្សនយោបាយគឺមាត្រា១៥ ដែលគណប្រតិភូបានលើកឡើងថាមន្រ្តីរាជការដែលបំរើការនៅតាមក្រសួងស្ថាប័នតែងតែយកម៉ោងធ្វើការរបស់រដ្ឋ និងធនធានរបស់រដ្ឋទៅបំរើអោយគណបក្សនយោបាយនៅពេលដែលប្រធានស្ថាប័នដែលជាសមាជិករបស់គណបក្សនយោបាយចេញទៅធ្វើសកម្មភាពបំរើអោយគណបក្សនយោបាយ ដែលធ្វើអោយមន្រ្តីនៅថ្នាក់ក្រោមនៃស្ថាប័ននោះចេញទៅតាមផងដែរ។

ទាក់ទងទៅនឹងច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្រ្តវិញ គណប្រតិភូនៃគណបក្សសមរង្ស៊ីសុំអោយមានការផ្លាស់ប្តូនៃសមាសភាពរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ដើម្បីធានានូវឯករាជ្យភាពនិងអព្យាក្រិត្យក្នុងការរៀបចំការបោះឆ្នោត។ ជាពិសេសការអោយមានសមាសភាពរបស់អង្គការសង្គមស៊ីវិល និងតំណាងមកពីគណបក្សនយោបាយដែលមានអសនៈនៅក្នុងរដ្ឋសភា ហើយសមាសភាពនេះមាននៅក្នុងគណៈកម្មាធិការរៀបចំការបោះឆ្នោតតាំងពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋាន។

បញ្ហាបារម្ភមួយទៀតដែលគណប្រតិភូនៃគណបក្សសមរង្ស៊ី បានលើកឡើងថាជាការសំខាន់ជាងគេគឺការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត។បញ្ជីឈ្មោះបោះឆ្នោតពេលបច្ចុប្បន្ននេះមានភាពខុសប្រក្រតីច្រើន ដែលមិនអាចទទួលយកបានឡើយចំពោះគណបក្សសមរង្ស៊ីជាពិសេសកាលប់ឈ្មោះស្ទួនអោយបានត្រឹមត្រូវ។ រីឯការចុះឈ្មោះបោះឆ្នោតវិញគណបក្សសមរង្ស៊ីសូម គ.ជ.ប ជាអ្នកធ្វើវិញ ពីព្រោះស្មានឃុំសង្កាត់គឺជាមន្រ្តីរបស់ក្រសួងមហាផ្ទៃដែលមិនអាចធានានូវភាពអព្យាក្រិត្យក្នុងការចុះឈ្មោះអោយប្រជាពលរដ្ឋដែលមាននិន្នាការនយោបាយផ្សេងៗពីគ្នាបានឡើយ។ គណប្រតិភូបានបន្តទៀតថាការបន្តប្រើប្រាស់នូវទម្រង់ ១០១៨ គឺរិតតែបន្តរគ្រួថ្នាក់ថែមទៀត គួរតែកាត់បន្ថយ ឬក៏ឈប់ប្រើប្រាស់ទម្រង់ ១០១៨តែម្តងគឺរិតតែល្អ។

គណប្រតិភូចង់អោយមានការបង្កើតស្ថាប័នមួយ សម្រាប់ដែលមានអំណាចឯករាជ្យចេញពី គ.ជ.ប សម្រាប់ដោះស្រាយវិវាទទាក់ទងទៅនឹងការបោះឆ្នោតរវាង គណបក្សនយោបាយ និងគណបក្សនយោបាយ ឬគណបក្សនយោបាយនិងមន្រ្តីរៀបចំការបោះឆ្នោត។ចំណែកឯប្រព័ន្ធផ្សព្វផ្សាយវិញ គឺត្រូវតែមានការបែងចែងម៉ោងអោយបានស្មើភាពគ្នាសម្រាប់គណបក្សនិមួយៗក្នុងការប្រើប្រាស់នូវប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ។ គណបក្សសមរង្ស៊ីគាំទ្រអោយមានការបង្កើតច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយនៅពេលឃោសនាបោះឆ្នោត ព្រោះច្បាប់នេះមានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់នូវការប្រើប្រាស់លុយដែលបានមកពីប្រភពខុសច្បាប់ដែលអាចជះឥទ្ធិពលមិនល្អដល់ការបោះឆ្នោត ហើយរដ្ឋមានតួនាទីឧបត្ថម្ភមកគណបក្សនយោបាយដែលមានអសនៈនៅក្នុងរដ្ឋសភា។

**គណបក្សសិទ្ធិមនុស្ស**

នៅក្នុងកិច្ចពិភាក្សាពិគ្រោះយោបល់នោះគណប្រតិភូនៃគណបក្សសិទ្ធិមនុស្សបានលើកឡើងថាកាព្រួយបារម្ភចំបងរបស់គណបក្សសិទ្ធិមនុស្ស គឺបញ្ជីបោះឆ្នោតដែលនៅក្នុងនោះមានឈ្មោះស្ទួន និងឈ្មោះដែលខុសអក្ខរាវិរុទ្ធជាច្រើនដែលកន្លងមក គ.ជ.ប មិនមានវិធានកា ច្បាស់លាស់ណាមួយលប់ឈ្មោះទាំងនោះអោយបានត្រឹមត្រូវទេ។ ទាក់ទងទៅនឹងការប្រើប្រាស់ទម្រង់១០១៨វិញ គណប្រតិភូបានស្នើសុំអោយឈប់ប្រើទម្រង់នេះតទៅទៀតហើយរកមធ្យោបាយផ្សេងប្រើជំនួសទម្រង់១០១៨នេះវិញ។

ទាក់ទងទៅនឹង គ.ជ.ប វិញ គណប្រតិភូ ចង់បានអោយមានសមាសភាពអង្គការសង្គមស៊ីវិលឯករាជ្យមាននៅក្នុងសមាជិកនៃ គ.ជ.ប ទើបធានាបាននូវឯករាជ្យ និងអព្យាក្រត្យនៃការរៀបចំការបោះឆ្នោត។ ក្រៅពីនេះក៏មានលើកឡើងផងដែរពីជនអន្តោប្រទេសន៍ដែលមានសិទ្ធិទៅបោះឆ្នោតបានដែរ។ រីឯការចេញប័ណ្ណព័ត៌មានវិញ នៅពេលដែលប្រជាពលរដ្ឋទៅចុះឈ្មោះ អ្នកចុះឈ្មោះត្រូវចេញនូវប័ណ្ណព័ត៌មានភ្លាមទៅអោយអ្នកមកមកចុះឈ្មោះ ហើយត្រូវដាក់ទោសចំពោះអ្នកចុះឈ្មោះណាដែលមិនធ្វើតាម។

ចំពោះសេរីភាពនៃការទទួលបានព័ត៌មានវិញ នៅមានកាលំបាកយ៉ាងខ្លាំងសម្រាប់អ្នកដែលចង់ស្វែងរកនូវព័ត៌មាន ឬទិន្នន័យពីសំណាក់ស្ថាប័ន រដ្ឋសភា គ.ជ.ប និងរដ្ឋាភិបាល ជាដើម ដើម្បីចង់ដឹងថាតើស្ថាប័នទាំងនោះបាន និងកំពុងធ្វើអ្វីខ្លះ ?ហើយសុំអោយអង្គការសង្គមស៊ីវិលជួយខាងសេរីភាពទទួលបានព័ត៌មាននេះផង។

**គណបក្សជាតិនិយម**

គណប្រតិភូនៃគណបក្សជាតិនិយមបានលើកឡើងថាចង់អោយមានការកែទម្រង់ គ.ជ.ប ដើម្បីអោយស្ថាប័ននេះមានឯករាជ្យ និងអព្យាក្រិត្យក្នុងការរៀបចំការបោះឆ្នោតអោយបានត្រឹមត្រូវ។គណប្រតិភូចង់បានសមាសភាពរបស់ គ.ជ.ប មានសមាសភាពចំរុះនៃគណបក្សនយោបាយតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម។ ចំណែកឯមន្ត្រីដែលជាអ្នកទទួលការចុះឈ្មោះបោះឆ្នោតវិញ ក៏ត្រូវតែផ្លាស់ប្តូរដែរពីព្រោះមន្ត្រីទាំងនោះជាមនុស្សរបស់គណបក្សនយោបាយ ។ រីឯការបោះឆ្នោតវិញ គណប្រតិភូចង់បានអោយដូចពីសម័យកាលអ៊ុនតាក់ ដែលប្រជាពលរដ្ឋនៅក្នុងខេត្តដែលចេញអត្តសញ្ញាណប័ណ្ណឲ្យ អាចទៅបោះឆ្នោតនៅការិយាល័យណាមួយក៏បាននៅក្នុងខេត្តនោះ។

គណបក្សជាតិនិយមសូមគាំទ្រនូវសិក្ខាសាលារបស់ខុមហ្វ្រែលដែលបានធ្វើកន្លងមក ទាក់ទងទៅនឹងកាបង្កើតក្របខ័ណ្ឌច្បាប់ស្តីពី ហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត

ដើម្បីអោយគណបក្សនិមួយៗប្រើប្រាស់ថវិការអោយបានត្រឹមត្រូវនិងតម្លាភាព។ ទាក់ទងទៅនឹងការអប់រំប្រជាពលរដ្ឋអំពីការបោះឆ្នោត គណប្រតិភូបានសំណូមពរអោយអង្គការក្រៅរដ្ឋាភិបាលជួយអោយកាន់តែខ្លាំងថែមទៀត ពីព្រោះមានប្រជាពលរដ្ឋច្រើនណាស់ដែលគាត់មិនបានយល់ដឹងពីបញ្ហាបោះឆ្នោតទាល់តែសោះ។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**



គណប្រតិភូតំណាងអោយ គ.ជ.ប បានមានប្រសាសន៍ថា គ.ជ.ប គឺជាស្ថាប័នដែលធ្វើការទៅតាមក្របខ័ណ្ឌច្បាប់ដែលបានកំណត់អោយ ហើយ គ.ជ.ប មិនជាស្ថាប័នដែលអាចធ្វើសេចក្តីស្នើរឬព្រាងច្បាប់បានឡើយ គ.ជ.ប គ្រាន់តែអាចលើកសំណើរទៅក្រសួងមហាផ្ទៃអំពីលទ្ធភាពក្នុងការកែប្រែឬមិនកែប្រែច្បាប់តែប៉ុណ្ណោះ។ គ.ជ.ប ក៏មានការលំបាកដែរចំពោះបញ្ជីបោះឆ្នោតប៉ោងដែលសព្វថ្ងៃនេះ គ.ជ.ប បានធ្វើការសហការណ៍ជាមួយនឹងក្រសួងមហាផ្ទៃដើម្បីធ្វើការលប់ឈ្មោះអោយបានត្រឹមត្រូវ ហើយក៏សុំកិច្ចសហប្រតិបត្តការពីខុមហ្វ្រែលផងដែរ។ ចំពោះការប្រើប្រាស់នូវទម្រង់១០១៨វិញ គ.ជ.ប ចង់បានការប្រើប្រាស់ស្របទៅតាមច្បាប់គឺមានរូបថត និងគល់បញ្ជីត្រឹមត្រូវនៅតាមឃុំសង្កាត់។

**គណបក្សហ្វុនស៊ិនប៉ិច**

គណប្រតិភូបានមានប្រសាសន៍ថា ការបោះឆ្នោតនៅប្រទេសកម្ពុជាគឺខុសពីប្រទេសដ៏ទៃពីព្រោះបញ្ហាជាច្រើនដែលទាក់ទងទៅនឹងការបោះឆ្នោតនៅកម្ពុជា គឺទាក់ទងទៅនឹងបញ្ហាបច្ចេកទេស។ ដូចជាការផ្តល់អត្តសញ្ញាណបណ្ណប្រជាពលរដ្ឋខ្មែរជូនប្រជាពលរដ្ឋដែលគ្រប់អាយុនៅមិនទាន់បានគ្រប់គ្នានៅឡើយ បញ្ជីឈ្មោះបោះឆ្នោតនៅមានឈ្មោះខ្មោច និងឈ្មោះស្ទួនច្រើន និងការជូនដំណឹងពីថ្ងៃបោះឆ្នោតជូនដល់ប្រជាពលរដ្ឋ។ ច្បាប់ដែលគ្រប់គ្រងក្នុងការប្រើប្រាស់នូវទម្រង់១០១៨មានភាពធូរលុង ដែលនៅពេលចាប់បានពីភាពមិនប្រក្រតីនៃការប្រើប្រាស់នូវទម្រង់១០១៨នេះ គឺតែងតែមានកាសម្របសម្រួល។ ការលប់ឈ្មោះខ្មោច ឬឈ្មោះស្ទួនមិនមានឯកសារបញ្ជាក់អោយបានច្បាស់លាស់មុននឹងធ្វើការលប់ជាផ្លូវការណ៍ ដែលទាំងអស់នេះជាបញ្ហា

បច្ចេកទេសសុទ្ធសាធដែលធ្វើអោយមានការប្រែប្រួលនៃលទ្ធផលនៃការបោះឆ្នោត។ កូនសិស្ស ដែលមានអាយុ ១៦ឬ១៧ឆ្នាំ ត្រូវបានគេយកមកហែក្បួនឃោសនាបោះឆ្នោតអោយគណបក្ស កាន់អំណាច ព្រមទាំងការប្រើប្រាស់មន្ត្រីរាជការ ឡាន និងប្រេងសាំងរបស់រដ្ឋថែមទៀតផងដែរ។

ជាចុងក្រោយគណប្រតិភូបានសំណូមពរអោយមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ ទាំងអស់គោរពច្បាប់អោយបានខ្ជាប់ខ្ជួន។ ចំណែកសមាសភាពរបស់គណៈកម្មាធិការជាតិរៀបចំ ការឆ្នោតវិញ គួរតែជាមនុស្សអព្យាក្រិត្យនៅគ្រប់កំរិតនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ជម្រើសទីពីរសម្រាប់សមាសភាពនេះគឺ តុល្យភាពនៃគណបក្សនយោបាយដែលមានអសនៈនៅ ក្នុងរដ្ឋសភាជាតិ។ គណប្រតិភូបានបន្តទៀតថាប្រសិនបើចំណុចទាំងនេះអាចធ្វើទៅបាន នឹងមាន ការផ្លាស់ប្តូរយ៉ាងធំធេងនៅពេលបោះឆ្នោតលើកក្រោយៗទៀត។

**តំណាងក្រសួងមហាផ្ទៃ**



គណៈប្រតិភូតំណាងក្រសួងមហាផ្ទៃបានលើកជាមតិថា គួរតែមានការវាយតម្លៃអោយបាន ច្បាស់លាស់មុននឹងធ្វើការរៀបចំសកម្មភាពអ្វីមួយ។គួរតែមានការពិគ្រោះអំពីនីតិវិធីមួយចំនួនដូច ជាបញ្ហាការចុះឈ្មោះអ្នកបោះឆ្នោត នីតិវិធីចុះឈ្មោះបោះឆ្នោត បញ្ជីឈ្មោះអ្នកបោះឆ្នោតប៉ោង និង បណ្តាញស្មៀនជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។បញ្ហាការបោះឆ្នោតព្រឹទ្ធសភា គួរ តែត្រូវអោយប្រជាជនស្វែងយល់ បើទោះជាវាមិនមានការពាក់ព័ន្ធដោយតែបញ្ហាប្រព័ន្ធបោះឆ្នោត វិញគឺអាស្រ័យទៅលើការយល់ដឹងរបស់ប្រជាជន។ គណៈប្រតិភូបានលើកឡើងពីប្រព័ន្ធបោះឆ្នោត ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន គួរតែមានប្រព័បន្ធចំរុះដែលអាចអោយអ្នកក្រ និងស្ត្រីក៏អាច ឈរឈ្មោះបានដែរ។ លោកបានបន្តទៀតថា គួរតែមានការអប់រំអ្នកបោះឆ្នោតដើម្បីអោយមាន និរន្តភាពដោយធ្វើចាប់តាំងពីមនុស្សវ័យក្មេងឡើងទៅ ដោយប្រធានបទពាក់ព័ន្ធនិងការបោះឆ្នោត និងប្រជាធិបតេយ្យ។

ទាក់ទងទៅនឹងកិច្ចសហប្រតិបត្តការណ៍ក្នុងការរៀបចំវេទិការនៅតាមខេត្ត លោកបានលើក ឡើងថា លោកគាំទ្រក្នុងដំណើរការនេះ ដោយគ្រាន់តែធ្វើលិខិត្តមកក្រសួងមហាផ្ទៃដើម្បីស្នើរវាគ្មិន ក្នុងការចូលរួមវេទិការដែលនឹងធ្វើនៅតាមខេត្តទាំងបួននោះ។

ឧបសម្ព័ន្ធទី ២. ការពិគ្រោះយោបល់នៅថ្នាក់ខេត្ត

២.១ ខេត្តបន្ទាយមានជ័យ

របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់ខេត្តបន្ទាយមានជ័យ

1. ពេលវេលានៃសកម្មភាពនៃការជួបប្រជុំពិភាក្សា

| ក្រុមដែលបានជួបពិភាក្សា | ទីកន្លែងពិភាក្សា | កាលបរិច្ឆេទ | រយៈពេល | សមាសភាពក្រុមជួបពិភាក្សា | សមាសភាព |
|---|---|---|---|---|---|
| គណបក្សប្រជាជនកម្ពុជា | មន្ទីរបក្ស | 08-09-2010 | 2ម៉ោង | ឯ. កែវ សុភាព<br>ឯ. គិម ស៊ាងអ៊ុន | លោកប្លង់ បឿត |
| គណបក្សសមរង្ស៊ី | មន្ទីរបក្ស | 06-09-2010 | ៣ម៉ោង | លោក ឱម ឈុនគ្រុយ<br>លោក ឈិន រិន<br>លោក កែវ សម្ផស្ស<br>លោក រិន រី | លោកប្លង់ បឿត |
| គណបក្សហ្វុនស៊ីនបិច | មន្ទីរបក្ស | | | ឯ. ញ៉ឹក គឹមឈុន | លោកប្លង់ បឿត |
| គណបក្សជាតិនិយម | មន្ទីរបក្ស | | | ឯ. ញ៉ឹក គឹមឈុន | លោកប្លង់ បឿត |
| គណបក្សសិទ្ធិមនុស្ស | | | | | លោកប្លង់ បឿត |
| គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត | ការិយាល័យ | 06-09-2010 | 1ម៉ោង៥0នាទី | លោក ហី គឹមសេង | លោកប្លង់ បឿត |
| គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត | ស្រុកមង្គលបូរី | 07-09-2010 | 1ម៉ោង៤៥នាទី | លោក ធុយ ចោម<br>លោក គិត ផល្លា | លោកប្លង់ បឿត |

| | | | | | |
|---|---|---|---|---|---|
| ស្មៀនឃុំ | ឃុំឬស្សីក្រោក | 07-09-2010 | 1ម៉ោង៤៥នាទី | លោក ចាន់ ប៊ុនធឿន<br>លោក អ៊ីវ សាលីន<br>លោក មិន ភារ៉ា | លោកប្លង់ បឿត |
| អង្គការក្រៅរដ្ឋាភិបាល | ខេ វ៉ាយ អេ | 06-09-2010 | 2ម៉ោង | លោក សុវណ្ណ សុភា<br>លោក អ៊ឹង យាម | លោកប្លង់ បឿត |
| ក្រុមប្រឹក្សាខេត្ត/ក្រុង | មន្ទីរបក្ស | 08-09-2010 | 2ម៉ោង | ឯ. កែវ សុភាព<br>ឯ. គិម ស៊ាងអ៊ុន | លោកប្លង់ បឿត |
| សាធារណៈជន | ទីស្នាក់ការខុមហ្វ្រែលខេត្ត | 09-09-2010 | 1ម៉ោង30នាទី | លោក សេង វណ្ណា<br>លោក យឿន កំសាន្ត<br>អ្នកស្រី ហី សុខហួន<br>កញ្ញា សៅ ពលក្ខណ៍ | លោកប្លង់ បឿត |

## 1. បញ្ហាដែលបានរកឃើញក្នុងអំឡុងពេលពិភាក្សា (បញ្ហាដែលកើតមានឡើង និងអនុសាសន៍)

### 1.1. បញ្ហាដែលក្រុមនិមួយៗបានលើកឡើង

#### 1.1.1. គណបក្សប្រជាជនកម្ពុជាក្រុមប្រឹក្សាខេត្ត/ក្រុង

ជារួមទាំងកំណែទម្រង់ការបោះឆ្នោត ក៏ដូចជាប្រជាធិបតេយ្យដែលត្រូវបានលើកឡើងភាគច្រើនមានភាពវិជ្ជ មានដូចជាប្រព័ន្ធបោះឆ្នោត និងការគណនាអសនៈតាមរូបមន្តសព្វថ្ងៃគឺជាការព្រមព្រាងរវាងអ្នកនយោបាយ។ ចំពោះការលើក ស្ត្រីចូលរួមក្នុងនយោបាយ កិច្ចការសង្គមគឺគណបក្សបានយកចិត្តទុកដាក់ទាំងនៅថ្នាក់ជាតិ និងមូលដ្ឋាន។ ចំពោះសមាសភាព គ.ជ.ប គឺអាស្រ័យលើច្បាប់កំណត់។ ទម្រង់១០១៨គឺជារឿងសំខាន់សម្រាប់អ្នកបោះឆ្នោតដែលមិនមានឯកសារគ្រប់គ្រាន់ និងប្រគល់ឱ្យស្មៀនធ្វើដដែល តែត្រូវពង្រឹងការអនុវត្តភារៈកិច្ចរបស់ស្មៀន។ រីឯប្រព័ន្ធផ្សព្វផ្សាយមានការអនុវត្តបានល្អ មានកាសែត វិទ្យុ ទូរទស្សន៍ទាំងរដ្ឋនិងឯកជន ហើយពេល បោះឆ្នោតក៏មានកម្មវិធីផ្សព្វផ្សាយសម្រាប់គ្រប់គណបក្ស ដែលបានចូលរួមប្រកួតប្រជែងតាមរយៈកម្មវិធីសមភាព និងសមធម៌។ ចំពោះដំណើរការបណ្តឹងបោះឆ្នោតគួរបន្តដោះស្រាយតាមការសំរបសំរួលឱ្យបានច្រើន។ ការគ្រប់គ្រង ហិរញ្ញវត្ថុគណបក្សនយោបាយគឺវាអាស្រ័យលើគណបក្សនយោបាយនីមួយៗ។ ចំណែកបញ្ហាពាក់ព័ន្ធប្រជាធិបតេយ្យយល់ថាល្អប្រសើរឡើងហើយទាំងការបញ្ចេញមិត សេរីភាពក្នុងការទទួល ព័ត៌មាន និងសេរីភាពក្នុង ការប្រមូលផ្តុំ ប៉ុន្តែយើងធ្វើអ្វីត្រូវអនុវត្ត និងគោរពទៅតាមច្បាប់។ មិនមានការចាត់អាទិភាព

បញ្ហាទេ ប៉ុន្តែលោក បានផ្តល់យោបល់ថា ត្រូវរកឱ្យឃើញពីចំណុចអសកម្មក្នុងចំណុចដែលបានលើកឡើង ហើយស្វែងរកដំណោះ ស្រាយរួមគ្នា។

### 1.1.2. គណបក្សសមរង្ស៊ី

ចង់ឱ្យអនុវត្តតាមប្រព័ន្ធឯកត្តនាម ហើយក៏ឯកភាពលើប្រព័ន្ធសមាមាត្រ ប៉ុន្តែត្រូវផ្តល់ឱកាសដល់បុគ្គលឯករាជ្យ បានចូលរួមដែរ។ ចំណែកការបែងចែកអសនៈគឺអាចយកការគណនាតាមរូបមន្តអ៊ុនតាក់ ឬមានរូបមន្តណាផ្សេង ទៀតដែលមានភាពស្មើគ្នា។ ហើយឯកភាពលើការកំណត់កូតាស្ត្រី៣០%នៅក្នុង គោលនយោបាយបក្ស តែមានការ បារម្ភអំពីការស្វែងរកស្ត្រីដែលហ៊ានចូលរួម។ គ.ជ.ប ចង់បានសមភាពតំណាងតាំងពីលើរហូតដល់ក្រោម។ ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតដូចជំនាន់ UNTAC ឬដូចឆ្នាំ១៩៩៨ ឬជំរុញការចេញអត្តសញ្ញាណប័ណ្ណ។ សុំឱ្យយក សមភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត។ ត្រូវមានតុលាការឯករាជ្យមួយសំរាប់ការបោះឆ្នោត មិនមែនគ.ជ.ប។ ហើយគាំទ្រឱ្យមានការកំណត់ និងបង្ហាញមូលនិធិគណបក្ស និងគាំទ្រឱ្យមានច្បាប់គ្រប់គ្រង ហិរញ្ញវត្ថុនយោបាយ។ ចំពោះការអប់រំអ្នកបោះឆ្នោតត្រូវតែ បន្តការអប់រំលើតំលៃនៃសន្លឹកឆ្នោត និងនិតិវិធី ឬដំណើរការបោះឆ្នោត។ សេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការប្រមូលផ្តុំ និងសេរីភាពទទួលព័ត៌នៅមិនទាន់បានល្អ មតិប្រឆាំងមិនត្រូវទៅពិចារណា ឬដោះស្រាយ និងមានការចាប់ដាក់គុកទៅលើអ្នកនយោបាយ និងប្រជាពលរដ្ឋដែលហ៊ានតវ៉ា។ មិនត្រូវចាត់ទុកការបរិហាកេរ្តិ៍ និងផ្តល់ព័ត៌មានមិនពិតជាបទល្មើសឧក្រិដ្ឋ។

បញ្ហាអទិភាពមានៈបញ្ហាសមាសភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បញ្ហាប្រព័ន្ធផ្សព្វ ផ្សាយ ជាពិសេសពេលឃោសនាបោះឆ្នោត និងការអប់រំអ្នកបោះឆ្នោត។ បញ្ហាពាក់ព័ន្ធនឹងប្រជាធិបតេយ្យ មានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការប្រមូលផ្តុំ។

### 1.1.3. គណបក្សហ្វុនស៊ីនប៉ិច/ជាតិនិយម

ចំពោះប្រព័ន្ធបោះឆ្នោតមួយណាក៏បានដែរ ប៉ុន្តែការរូបមន្តគណនាអសនៈសម័យ UNTAC មានលក្ខណៈល្អប្រសើរ សម្រាប់ការអនុវត្តន៏។ មានការគាំទ្រឱ្យមានការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងសង្គម។ គណបក្សបានយកចិត្តទុកដាក់ និងកំណត់កូតាស្ត្រីក្នុងកំរិតគោលនយោបាយបក្សទាំងថ្នាក់ជាតិ និងមូលដ្ឋាន។ ចង់ឱ្យមានការបែងចែកជាកូតាសម្រាប់សមាសភាពគ.ជ.ប នៅថ្នាក់ជាតិ ថ្នាករាជធានី ខេត្ត និងថ្នាក់ឃុំសង្កាត់ ដែលអាចទទួលយកបានទាំងអស់គ្នា តែមានការពិបាករកមនុស្សឯករាជ្យមកធ្វើកិច្ចការនេះណាស់។ នៅថ្នាក់ជាតិគួរតែកំណត់ពីអាណត្តិ។ ចំណែកឯការចេញទម្រង់១០១៨ ត្រូវមានបញ្ជីស្នាមត្រឹមត្រូវ និងជម្រុញការចេញអត្តសញ្ញាណប័ណ្ណ និងធ្វើឱ្យបានត្រឹមត្រូវ។ ការលប់ឈ្មោះត្រូវតែមានស្រាវជ្រាវឬសាកសួរព័ត៏មាន និងមានការចូលរួមពីសង្គមស៊ីវិល និងគណបក្សនយោបាយ។

ការដោះស្រាយបណ្ដឹងគឺមិនបានត្រឹមត្រូវទេ នេះគឺមកពីការជ្រើសរើសគ.ជ.ប.។ ចំពោះការគ្រប់គ្រង ហិរញ្ញវត្ថុប្រសិនបើមានក៏ជាការល្អ(ការសម្រេចចិត្តហាក់ដូចជាមិនច្បាស់)។ សេរីភាពបញ្ចេញមតិនៅមានកំរិត ហើយ មិនត្រូវកំណត់ការផ្សព្វផ្សាយព័ត៌មានមិនពិត និងបរិហាកេរ្តិ៍មិនត្រូវចាត់ទុកជាបទឧក្រិដ្ឋ។ ចំពោះបញ្ហា អាទិភាពដែលបានលើកឡើងមានតែសមាសភាព គ.ជ.ប និងសេរីភាពបញ្ចេញមតិ ។

### 1.1.4. គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត

ប្រព័ន្ធសមាមាត្រល្អសំរាប់កម្ពុជាបច្ចុប្បន្ន។ មានការគាំទ្រឱ្យមានការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និង សង្គម ទាំងគណបក្សនយោបាយ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធត្រូវបន្តយកចិត្តទុកដាក់ពង្រឹងសមត្ថភាព និងលើក ទឹកចិត្តដល់ស្ត្រីទាំងគោលនយោបាយ និងការអនុវត្តជាក់ស្តែង។ ចំពោះសមាសភាព គ.ជ.ប និងការអនុវត្តសកម្ម ភាពគឺបានធ្វើទៅតាមច្បាប់ ប៉ុន្តែសមាសភាពនៅមូលដ្ឋានតំបន់ដាច់ស្រយាលគឺអាចមានកម្រិត។ មិនគួរឱ្យមាន ការកំណត់ស្តង់ដាចំពោះអង្គាធរបោះឆ្នោតថ្នាក់ក្រោមទេ តែយើងរើសទៅតាមកន្លែងណា ហើយកំណត់យកកំរិតណា។ ចំពោះ ទម្រង់១០១៨ ជារឿងសំខាន់សម្រាប់ដែលត្រូវបន្តការប្រើប្រាស់ តែពង្រឹងនីតិវិធី និងការគ្រប់គ្រងនៃការចេញទម្រង់នេះ។ ការលុបឈ្មោះតែត្រូវធ្វើការសាកសួរ និងឯកសារ យោងជាពិសេសពង្រឹងការទទួលខុសត្រូវរបស់មេភូមិ និងស្មៀនឡើងវិញ។ ការផ្សព្វផ្សាយមានលក្ខណៈល្អប្រសើរហើយ ហើយបានផ្តល់ឱកាសដល់ គណបក្សនយោបាយតាមកម្មវិធីសមភាព និងសមធម៌។ ចំពោះការដោះស្រាយបណ្តឹងបានអនុវត្តតាមបទបញ្ជា និងនីតិវិធីមិនថាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។ គួរតែមានការកំណត់ និងបង្ហាញពីប្រភពមូលនីធិគណបក្ស ឬបេក្ខជនគណបក្សនយោបាយជាសាធារណៈ ហើយគួរតែដាក់ចូលក្នុងច្បាប់បោះឆ្នោត និងមានក្រុមសវនកម្មឯករាជ្យ។ គួរតែបន្តការអប់រំអ្នកបោះឆ្នោតជាពិសេសលើកំពស់ការយល់ដឹង និងលើកទឹកចិត្តឱ្យគាត់ទៅពិនិត្យបញ្ជីឈ្មោះ។ សេរីភាពបញ្ចេញមតិ និងទទួលបានព័ត៌មានមិនទាន់បានល្អនៅឡើយ។

បញ្ហាអាទិភាពៈ បញ្ជីឈ្មោះ និងការចុះឈ្មោះអ្នកបោះឆ្នោត ការគ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយ និងការអប់រំអ្នកបោះឆ្នោត។ ម្យ៉ាងវិញទៀតបញ្ហាពាក់ព័ន្ធនឹង ប្រជាធិបតេយ្យដែលបានលើកឡើងមាន សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការទទួលព័ត៌មាន។

### 1.1.5. គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត

ប្រព័ន្ធបោះឆ្នោតរាល់ថ្ងៃគឺប្រសើរហើយ។ គាំទ្រឱ្យស្ត្រីបានចូលរួមក្នុងនយោបាយ និងសង្គមបានច្រើន។ សមាសភាព គ.ជ.ប បានធ្វើតាមច្បាប់។ នៅថ្នាក់ឃុំមានការជ្រើសរើសតាមការប្រកួតប្រជែងសមត្ថភាពទៅតាមការណែនាំ និងនីតិវិធី។ ចំពោះទម្រង់១០១៨នៅតែជារឿងសំខាន់ដោយសារតែប្រជាពលរដ្ឋយើងមួយចំនួន មិនមានឯកសារបញ្ជាក់អត្តសញ្ញាណនៅថ្ងៃបោះឆ្នោត ម្យ៉ាងវិញទៀតការចេញអត្តសញ្ញាណប័ណ្ណមិនទាន់បានគ្រប់គ្នា។ ការចុះឈ្មោះ

អ្នកបោះឆ្នោតគួរគ.ជ.ប ចាត់តាំងមន្ត្រី គ.ឃ.ប ម្នាក់ដើម្បីធ្វើកិច្ចការនេះជាមួយក្រុមប្រឹក្សាឃុំ ឬស្មៀន ដើម្បី បានប្រសើរ។ចំពោះប្រព័ន្ធផ្សព្វផ្សាយ និងការដោះស្រាយបណ្តឹងកន្លង មកយើងមិនបាន នឹងស៊ីជំរៅទេនៅថ្នាក់ជាតិ ប៉ុន្តែនៅតាមការិយាល័យ និងកម្រិតឃុំ ខេត្ត បានអនុវត្តយ៉ាងប្រសើរ។គួរមានច្បាប់គ្រប់គ្រងហិរញ្ញ គណបក្ស នយោបាយ ការកំណត់ចំណាយរបស់គណបក្សនយោបាយ ជាពិសេសពេលឃោសនាបោះឆ្នោត។ សេរីភាពក្នុងការបញ្ចេញមតិ ទទួលព័ត៌មាន និងការប្រមូលផ្តុំអាចទទួលយកបាន ប្រជាពលរដ្ឋមានការតវ៉ា និងបាតុកម្មទាមទា អ្វីដែលជាគេចង់បាន ប៉ុន្តែក៏មានការទប់ស្កាត់ខ្លះដែរ។ មិនត្រូវចាត់ទុកការបរិហាកេរ្តិ៍ និងផ្តល់ព័ត៌មានមិនពិតជាបទ ល្មើសឧក្រិដ្ឋ។

បញ្ហាអាទិភាពមានៈបញ្ហាសមាសភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ការដោះស្រាយ បណ្តឹងបោះឆ្នោត និងការគ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយ។ ម្យ៉ាងវិញទៀតបញ្ហាពាក់ព័ន្ធ នឹងប្រជាធិបតេយ្យដែលបានលើកឡើងមាន សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាព ក្នុងការ ទទួលព័ត៌មាន។

### 1.1.6. ស្មៀនឃុំ

អនុវត្តន៍តាមប្រព័ន្ធបោះឆ្នោតដែលមានស្រាប់កន្លងមក និងគាំទ្រការចូលរួមរបស់ស្ត្រីក្នុងនយោបាយ និងសង្គមឱ្យ បានកាន់តែច្រើន។ មិនបានដឹងច្បាស់ពីនីតិវិធីនៃការជ្រើសរើសគ.ជ.ប ប៉ុន្តែមានគណៈកម្មការចម្រុះក្នុងការជ្រើសរើស ក៏ជាការប្រសើរដែរ។ នៅថ្នាក់ឃុំមានការជ្រើសរើសតាមការប្រកួតប្រជែងសមត្ថភាពទៅតាមការណែនាំ និងនីតិវិធី។ ការចុះឈ្មោះអ្នកបោះឆ្នោតកន្លងមកជួបការលំបាកដែរ ដូចជាផ្តល់ទិន្នន័យខុសទីតាំង ពិបាករកឯកសារយោងដើម្បី លប់ឈ្មោះ ការប្រើប្រាស់ឯកសារផ្សេងគ្នាពេលទៅចុះឈ្មោះ និងទៅបោះឆ្នោត ប្រជាពលរដ្ឋមិន យកចិត្តទុកដាក់ និងមិនចាប់អារម្មណ៍។ រីឯការបញ្ចូលទិន្នន័យការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត គួរថ្នាក់ខេត្តនីមួយៗធ្វើ ព្រោះវាងាយស្រួលក្នុងការផ្ទៀងផ្ទាត់។ បង្កើនរយៈពេលនៃការចុះ ឈ្មោះ និងពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ១០ឬ១៥ថ្ងៃបន្ថែមទៀត។ ស្ថានភាពបច្ចុប្បន្ន ទម្រង់១០១៨នៅតែចាំបាច់សំរាប់ប្រជាពលរដ្ឋដែលមិនមានឯកសារគ្រប់គ្រាន់។ ការដោះស្រាយបណ្តឹងនៅថ្នាក់ការិយាល័យ និងគ.ឃ.ប មិនមានបញ្ហាអ្វីទេ។ ប្រសិនបើមាន តុលាការសម្រាប់ដោះ ស្រាយវិវាទបោះឆ្នោតមួយដោយឡែកពេលបោះឆ្នោតក៏ល្អដែរ។ គាំទ្រឱ្យមានការគ្រប់គ្រង ហិរញ្ញវត្ថុ គណបក្សនយោបាយ ជាពិសេសពេលបោះឆ្នោត។ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ហើយការអប់រំផ្សព្វផ្សាយ មិនបានទូលំទូលាយជាពិសេសនៅតាមតំបន់ដាច់ស្រយាល។ សេរីភាព ក្នុងការបញ្ចេញមតិទទួលព័ត៌មាន និងការ ប្រមូលផ្តុំមានការប្រសើរជាងមុនបណ្តើរៗ ហើយមិនត្រូវចាត់ទុកការបរិហាកេរ្តិ៍ និងផ្តល់ព័ត៌មាន មិនពិតជាបទ ល្មើសឧក្រិដ្ឋ ការផាកពិន័យជាលុយកាក់បានហើយ។

បញ្ហាអាទិភាពគឺៈ បញ្ហាបញ្ជីឈ្មោះ និងការចុះឈ្មោះអ្នកបោះឆ្នោត បញ្ហាប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសពេល ឃោសនាបោះឆ្នោត និងការអប់រំអ្នកបោះឆ្នោត។ ម្យ៉ាងវិញទៀតបញ្ហាពាក់ព័ន្ធនឹង ប្រជាធិបតេយ្យដែលបាន លើកឡើងមានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាព ក្នុងការប្រមូលផ្តុំ។

### 1.1.7. អង្គការក្រៅរដ្ឋាភិបាល

ប្រព័ន្ធបោះឆ្នោតគួរតែអនុវត្តប្រព័ន្ធឯកត្តនាម ឬប្រព័ន្ធចំរុះដើម្បីបានបុគ្គល ឬក្រុម ឯករាជ្យចូលរួមប្រកួតប្រជែង។ ការកំណត់កូតាស្ត្រីគឺការល្អ ប៉ុន្តែវាអាស្រ័យទៅលើសមត្ថភាព និងមានការលើកទឹកចិត្ត ហើយគណបក្សនយោបាយនីមួយៗត្រូវមានគោលនយោបាយ និងការ អនុវត្តឱ្យបានល្អប្រសើរ។ សមាជិក គ.ជ.ប មិនទាន់មាន ឯករាជ្យភាពនៅឡើយ បើមើល ក្នុងក្របខ័ណ្ឌច្បាប់បានធានាពីឯករាជ្យភាពរបស់សមាជិក គ.ជ.ប ប៉ុន្តែបុគ្គលខ្លួន ឯងនោះមិន ឯករាជ្យ។ នីតីវិធីរបស់គ.ជ.បនៅមានការលំបាកសំរាប់ប្រជាពលរដ្ឋនៅឡើយជាពិសេស ទៅ លើការ ចេញឯកសារបញ្ជាក់អត្តសញ្ញាណ។ គួរតែបន្តប្រើប្រាស់ទម្រង់ ១០១៨ ហើយចំពោះការ ធ្វើប្រតិភូកម្មអំណាចឱ្យ ស្មៀនក្នុងការចុះឈ្មោះបោះឆ្នោត ត្រូវមានការត្រួតពិនិត្យ និងតាមដានឱ្យ បានមឹងម៉ាត់ និងត្រូវមានការចូលរួមផងដែរពីភ្នាក់ងារគណបក្សនយោបាយនីមួយ និងសង្គម ស៊ីវិល។ ចំពោះការផ្សព្វផ្សាយកន្លងមកទូរទស្សន៍ជាតិ កម្ពុជាបានអនុវត្តន៍ល្អប្រសើរហើយ ប៉ុន្តែ ចំពោះទូរទស្សន៍ឯកជននៅតែមានភាពលំអៀងក្នុងការផ្សព្វផ្សាយ។ ការបែងចែកនាទីក្នុងព័ត៌មាន សមធម៌មានភាពអយុត្តិធម៌ គួរតែមានការបែងចែកឱ្យបានស្មើៗគ្នា។ ចំពោះការដោះស្រាយបណ្ដឹង មិនសំខាន់លើការបង្កើតឱ្យមានគណៈកម្មការដោយឡែកទេ វាសំខាន់គឺ គណៈកម្មាធិការ រៀបចំការ បោះឆ្នោតគ្រប់លំដាក់ថ្នាក់ឯករាជ្យ។ ចំពោះហិរញ្ញវត្ថុគណបក្សនយោបាយគួរតែ មានការកំណត់ការចំណាយរបស់ គណបក្សនយោបាយនីមួយៗពេលបោះឆ្នោត។ សេរីភាពក្នុង ការបញ្ចេញមតិ មិនទាន់បានទូលំទូលាយនៅឡើយ ដោយមានការគៀបសង្កត់ពីអ្នកនយោបាយ អ្នកមានអំណាច។ អំពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងបទបរិហាកេរ្តិ៍គួរតែកុំមានការ ដាក់ពន្ធនាគារ គ្រាន់តែធ្វើ ការកែតម្រូវ និងផាកពិន័យជាប្រាក់។ សេរីភាពទទួលព័ត៌មាន ក៏នៅមានភាពចង្អៀតនៅឡើយ។ ប្រជាពលរដ្ឋនៅ មិនទាន់មានសេរីភាពគ្រប់គ្រាន់ក្នុង ការប្រមូលផ្តុំនៅឡើយ ព្រោះតែងតែមានការកំណត់ឱ្យមានការស្នើសុំច្បាប់ មានការរារាំង បំបែក និងហាមឃាត់។

បញ្ហាអាទិភាពមានៈ បញ្ហាប្រព័ន្ធបោះឆ្នោត បញ្ហាសមាសភាពរបស់គណៈកម្មាធិការ ជាតិរៀបចំការ បោះឆ្នោត (គ.ជ.ប) និងការគ្រប់គ្រង ហិរញ្ញវត្ថុគណបក្សនយោបាយ។ ម្យ៉ាងវិញទៀតបញ្ហាពាក់ព័ន្ធនឹង ប្រជាធិបតេយ្យ ដែលបានលើកឡើងមានសេរីភាព ក្នុងការបញ្ចេញមតិ និងសេរីភាពក្នុង ការប្រមូលផ្តុំ។

### 1.1.8. សាធារណៈជន

ចង់បានប្រព័ន្ធឯកត្តនាម គិតពីប្រយោជន៍ប្រជាពលរដ្ឋជាងប្រយោជន៍គណបក្ស។ ការជ្រើសរើស មន្ត្រីការិយាល័យ គ.ឃ.ប និងការិយាល័យបោះឆ្នោត មានភាពលំអៀង។ រយៈកាលកន្លងមកធ្លាប់ជួបបញ្ហាការ បាត់ឈ្មោះអ្នកបោះឆ្នោត។ គួរតែមានការចាត់តាំងមន្ត្រីរបស់ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យការងាររបស់ស្មៀនក្នុងការចុះឈ្មោះបោះឆ្នោត។ គួរតែមានការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតាមភូមិ ព្រោះអ្នកបោះឆ្នោតនៅតំបន់ដាច់ស្រយាលមានការលំបាកក្នុងការទៅពិនិត្យ ឈ្មោះនៅសាលាឃុំ។ ការផ្សព្វផ្សាយមិនទាន់បានទូលាយ។ សេរីភាពក្នុងការបញ្ចេញមតិ និងទទួលព័ត៌មាន នៅមិនទាន់បានគ្រប់គ្រាន់ទៅតាមការទាមទាររបស់ប្រជាពលរដ្ឋដូចជា រឿងដីធ្លី។

បញ្ហាជាអាទិភាពមានៈ បញ្ហាប្រព័ន្ធបោះឆ្នោត បញ្ហាប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសពេលឃោសនាបោះឆ្នោត និងការ គ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយ។ ម្យ៉ាងវិញទៀត បញ្ហាពាក់ព័ន្ធនឹង ប្រជាធិបតេយ្យ ដែលបានលើក ឡើងមានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការទទួលព័ត៌មាន។

បញ្ហាអាទិភាពចំនួន៥ សម្រាប់ខេត្តបន្ទាយមានជ័យទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោត និងប្រជាធិប្បតេយ្យមានៈ សមាសភាពគ.ជ.ប ប្រព័ន្ធផ្សព្វផ្សាយ ការគ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយ សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការប្រមូលផ្តុំ។

២.២ ខេត្តសៀមរាប

**របាយការណ៍នៃកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់ខេត្តសៀមរាប**

2. **ពេលវេលានៃសកម្មភាពនៃការជួបប្រជុំពិភាក្សា**

| **ក្រុមដែលបានជួបពិភាក្សា** | **ទីកន្លែងពិភាក្សា** | **កាលបរិច្ឆេទ** | **រយពេល** | **សមាសភាពក្រុមជួបពិភាក្សា** | **សមាសភាព** |
|---|---|---|---|---|---|
| គណបក្សប្រជាជនកម្ពុជា | ស្នាក់ការគណបក្សខេត្ត | 09-09-10 | 01m | ឯ.អ៊ឹង ហឿង អនុប្រធានបក្ស ខេត្ត | -កុយ ច័ន្ទដារិទ្ធ<br>- ម៉ៅ យិន<br>- ផល ប៊ុនគី |
| គណបក្សសមរង្ស៊ី | ស្នាក់ការគណបក្សខេត្ត | 06-09-10 | 2m 30n | ឯ. សម សែន ប្រធានស្តីទីបក្ស ខេត្ត និងសហការី៥រូបទៀត | ដដែល |
| គណបក្សហ្វុនស៊ីនបិច | ស្នាក់ការគ | 07-09- | 2m | ឯ. អ៊ុំ សុមន្ទា | ដដែល |

| | | | | | |
|---|---|---|---|---|---|
| | ណបក្ស ខេត្ត | 10 | 30n | អនុប្រធានបក្ស ខេត្ត | |
| គណបក្សជាតិនិយម | ផ្ទះសកម្មជនគណបក្សខេត្ត | 06-09-10 | 2m 30n | លោក ឡាំ ទិញ អនុប្រធានបក្ស ខេត្ត និងសហការី ៦រូប | ជដែល |
| គណបក្សសិទ្ធិមនុស្ស | ផ្ទះសកម្មជនគណបក្សខេត្ត | 07-09-10 | 3m 30n | លោក សេង ហាប់ អនុប្រធានប្រតិបត្តបក្សខេត្តនិងសហការី៣រូប | ជដែល |
| គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត | ស្នាក់ការ គ.ខ.ប | 08-09-10 | 2m 30n | លោក នឹម វ៉ាន់សំ ប្រធាន លោក ពៅ សាខន អនុប្រធាន | ជដែល |
| គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត | ផ្ទះអតីតប្រធាន គ.ឃ/ស.ប ឃុំសពោង យោង ស្រុកពួក | 08-09-10 | 1m 20n | លោក ជួង ជុសុជាតិ អតីតប្រធាន គ.ឃ/ស.ប អ្នកស្រី ឡាន់ សារឹទ្ធ អតីតប្រធាន គ.ឃ/ស.ប | ជដែល |
| ស្មៀនឃុំ | ស្នាក់ការ ឃុំខ្នាត ស្រុកពួក | 08-09-10 | 01m | លោក មឿន ធុំ ស្មៀន លោក នៅ នា ស្មៀន លោក ហឿង ហាត់ ស្មៀន | ជដែល |
| អង្គការក្រៅរដ្ឋាភិបាល | ស្នាក់ការអាដហុកខេត្ត | 09-09-10 | 1m 45n | តំណាងណអឿស ក្នុងខេត្ត ជាដៃគូខុមហ្វ្រែលខេត្ត ៥រូប | ជដែល |
| ក្រុមប្រឹក្សាខេត្ត/ក្រុង | ការិយាល័យក្រុម ប្រឹក្សាខេត្ត | 09-09-10 | 2m | ឯ. កៅ សោភ័ណ្ឌ សមាជិកក្រុម | ជដែល |

| | | | | | |
|---|---|---|---|---|---|
| | | | | ប្រឹក្សាខេត្ត | |
| សាធារណៈជន | ស្នាក់ការអាជហុក ខេត្ត | 09-09-10 | 1m 40n | តំណាងប្រជាពលរដ្ឋ ខេត្ត សៀមរាបចំនួន ៦ រូប | ដដែល |

2. បញ្ហាដែលបានរកឃើញក្នុងអំឡុងពេលពិភាក្សារ (បញ្ហាដែលកើតមានឡើងនិងអនុសាសន៍)

2.1.1. បញ្ហាដែលក្រុមនិមួយៗបានលើកឡើង

2.1.2. គណបក្សប្រជាជនកម្ពុជា

គាំទ្រឱ្យប្រើប្រព័ន្ធសមាមាត្រ និងគណនាអសនៈតាមរូបមន្តដដែល។ គណបក្សបានកំណត់ច្បាស់ក្នុងលទ្ធផលនៃមហាសន្និបាទបក្ស ក្នុងការលើក ស្ទួយស្ត្រីឱ្យឈរឈ្មោះក្នុងលំដាប់ដែលអាចជាប់ឆ្នោតបាន។ ចំពោះសមាសភាព គ.ជ.ប គឺអាស្រ័យលើច្បាប់កំណត់ទាំងគ្រប់កំរិត។ នៅតែគាំទ្រ ឱ្យប្រើទំរង់១០១៨ និងប្រគល់ឱ្យស្មៀនធ្វើដដែល តែត្រូវពង្រឹងការអនុវត្តភារកិច្ចរបស់ស្មៀន។ រីឯប្រព័ន្ធផ្សព្វផ្សាយគួរអនុវត្តតាមសមភាព។
ចំពោះដំណើរការបណ្តឹងបោះឆ្នោតគួរបន្តដោះស្រាយតាមការសំរបសំរួលឱ្យបានច្រើន។ មិនឯកភាពក្នុងការកំណត់មូនិធិគណបក្ស ឬបេក្ខជនទេ គួរអនុវត្តដូចកន្លងមក។ ចំណែកបញ្ហាពាក់ព័ន្ធប្រជាធិបតេយ្យយល់ថាល្អគ្រប់គ្រាន់ តែគាំទ្រឱ្យមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបានឆាប់ កាន់តែល្អ។ បញ្ហាអទ្ធិភាពទាំង៥មានៈ ការចុះឈ្មោះ ប្រព័ន្ធផ្សព្វផ្សាយ ការអប់រំអ្នកបោះឆ្នោត សិទ្ធិទទួលព័ត៌មាន និងសិទ្ធិប្រមូលផ្តុំ។ ឯកភាពលើគំរូវេទិកា តែសុំឱ្យមានការសុំច្បាប់និងបញ្ជាក់អំពីគោលបំណងនៃវេទិកាឱ្យបានច្បាស់ដាក់ទៅប្រធានបក្សខេត្ត។

2.1.3. គណបក្សសមរង្ស៊ី

គួររក្សាការប្រើប្រព័ន្ធសមាមាត្រ តែយកការគណនាតាមរូបមន្តអ៊ុនតាក់ ហើយឯកភាពលើការកំណត់កូតាស្ត្រី៣០%នៅក្នុង គោលនយោបាយបក្ស តែមានការបារម្ភអំពីការស្វែងរកស្ត្រីដែលហ៊ានចូលរួម។ គ.ជ.ប ចង់បានសមភាពតំណាងតាំងពីលើរហូតដល់ក្រោម។ មិនគួរកំណត់ស្តង់ដាចំពោះ គ.ឃ/ស.បទេ តែសំខាន់បង្កើនការបណ្តុះបណ្តាលពួកគេឱ្យបានគ្រប់គ្រាន់។ សុំលប់ចោលបញ្ជីឈ្មោះចាស់ ហើយចុះថ្មីដោយ គ.ជ.ប ដូចឆ្នាំ១៩៩៨ ឬជំរុញការចេញអត្តសញ្ញាណប័ណ្ណហើយប្រើបញ្ជីចេញដោយមហាផ្ទៃ។ សុំឱ្យយកសមភាពក្នុងការ ប្រើប្រាស់ប្រព័ន្ធ ផ្សព្វផ្សាយក្នុងពេលបោះឆ្នោត។ ត្រូវមានតុលាកាឯករាជ្យមួយសំរាប់ការបោះឆ្នោតមិនមែន គ.ជ.ប។ ហើយគាំទ្រឱ្យមាន ការកំណត់ និង បង្ហាញមូលនិធិគណបក្ស និងគាំទ្រឱ្យមានច្បាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយ។ ចំពោះការអប់រំអ្នកបោះឆ្នោតត្រូវតែបន្តការអប់រំលើតំលៃនៃសន្លឹកឆ្នោត និងនិតិវិធី ឬដំណើរការបោះឆ្នោត។ ប្រជាធិបតេយ្យគឺ ប្រសើជាងមុនតែនៅមានកំរិតគួរតែបើកទូលាយជាងនេះ និងត្រូវតែ យកមតិប្រឆាំងទៅពិចារនា ឬដោះស្រាយ។

ចំពោះសេរីភាពទទួលព័ត៌មានមិនពេញចិត្តសោះត្រូវតែចាត់ជាអទិ្ធភាពក្នុងអណតិទី៤នេះ។ គួរធ្វើវិសោធនកម្មច្បាប់បាតុកម្ម។

បញ្ហាអទិ្ធភាព៥គឺ ៖ សមាសភាព គ.ជ.ប ប្រព័ន្ធផ្សព្វផ្សាយ បញ្ជីឈ្មោះបោះឆ្នោត សេរីភាពទទួលព័ត៌មាន និងសេរីភាពបញ្ចេញមតិ។ ឯកភាពទាំងស្រុងលើគំរូរៀបចំដំណើរការវេទិកា និងរីករាយសហការណ៍ចូលរួម។

### 2.1.4. គណបក្សហ្វុនស៊ីនប៉ិច

ចង់ឱ្យប្រើប្រព័ន្ធបោះឆ្នោតចំរុះ ឬសមាមាត្រតែយករូបមន្តគណនាតាមអ៊ុនតាក់ ហើយឯកភាពឱ្យមានការកំណត់កូតាស្ត្រីក្នុងកំរិត គោល នយោបាយបក្ស។ ចង់ឱ្យគ.ជ.ប កើតចេញពីការជ្រើសរើសពីគណៈកម្មការឯករាជ្យចំរុះភាគីពាក់ព័ន្ធ ហើយធ្វើរបៀបនេះតាំងពីលើដល់ ក្រោម និងគួរបង្កើតក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ គួរកំណត់អណតិ៥ឆ្នាំម្តង និងកំណត់ស្តង់ដារបស់ គ.ជ.ប ។ បញ្ឈប់ការប្រើប្រាស់ទំរង់ ១០១៨ ជំរុញការចេញ អត្តសញ្ញាណប័ណ្ណ ឬពង្រឹងសមត្ថភាពស្មៀនឡើងវិញ។ ការចុះឈ្មោះគួរគ្រប់គ្រងដោយ គ.ជ.ប វិញ ហើយស្មៀនជាចំនួយការវិញ។ ចំណែកការលប់ឈ្មោះត្រូវតែគ្រប់គ្រងដោយគ.ជ.ប ដោយសហការជាមួយស្មៀន ហើយគួតែមានកាត ឬប័ណ្ណសំរាប់កាន់ទៅបោះឆ្នោត។ ប្រព័ន្ធបោះឆ្នោតគួរយកសមភាពទាំងអស់។ ការដោះស្រាយបណ្តឹងគឺមិនបានត្រឹមត្រូវទេ គួរមានតុលាកាឯករាជ្យមួយសំរាប់ការបោះឆ្នោត ឬនីតិវិធីបណ្តឹងគួកំណត់ត្រឹមខេត្តបានហើយ។ ឯកភាពក្នុងការកំណត់ និងបង្ហាញប្រភពមូលនិធិគណបក្ស ឬបេក្ខជនតែកំណត់កំរិតអតិបរិមា អាចមានគុណវិបត្តិត្រង់ថាគណបក្សក្រអាចខាតបាត់ការគាំទ្រ។ គាំទ្រឱ្យមានច្បាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយ។ ប្រជាធិបតេយ្យសេរីភាព បញ្ចេញមតិនៅមានកំរិតតែប្រសើជាងមុន តែគួរកំរិតត្រឹមការបញ្ចេញមតិកែលំអរ ហើយបើមានការចាក់ផ្សាយមតិប្រឆាំងជាការប្រសើរ ។ ចំពោះសេរីភាពទទួលព័ត៌មានមិនទូលំទូលាយទេមានកំរិត គាំទ្រឱ្យចាត់ទុកច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានក្នុងអណតិទី៤នេះ។ ឯសេរីភាពប្រមូល ផ្តុំមិនពេញចិត្តទេ គឺអាចឱ្យប៉ះពាល់ដល់ប្រជាធិបតេយ្យ និងការបោះឆ្នោត ហើយគាំទ្រឱ្យមានការណែនាំមួយច្បាស់លាស់ដល់អ្នកអនុវត្តច្បាប់ និងអជ្ញាធរមូលដ្ឋាន។ ឯកភាពទាំងស្រុងលើគំរូរៀបចំវេទិកា និងត្រៀមខ្លួនសហការណ៍ចូលរួម។

ចំណុចជាអទិ្ធភាព៥មានៈ ប្រព័ន្ធបោះឆ្នោត សមាសភាព គ.ជ.ប ការអប់រំអ្នកបោះឆ្នោត សេរីភាពបញ្ចេញមតិ និងសេរីភាពទទួលបានព័ត៌មាន។

### 2.1.5. គណបក្សជាតិនិយម

នៅតែគាំទ្រឱ្យប្រើប្រព័ន្ធបោះឆ្នោតសមាមាត្រ តែគណនាអសនៈតាមរូបមន្តអ៊ុនតាក់ និងគាំទ្រឱ្យមានការកំណត់កូតាស្ត្រី៣០%។ ចំពោះ គ.ជ.ប គួរមានគណៈកម្មការឯករាជ្យមួយដែលមានសមាសភាពចំរុះ និងត្រូវយកអន្តរជាតិឱ្យធ្វើជាប្រធាន ឬសមភាពតំណាងពីលើដល់ក្រោម។ ស្ថាប័នគ.ជ.ប គួបង្កើតឡើងកំរិតច្បាប់រដ្ឋធម្មនុញ្ញ និងកំណត់អណតិ៥ឆ្នាំម្តង

ហើយក៏ត្រូវកំណត់ស្តង់ដាចំណេះដឹងខ្ពស់ និងមិន លំអៀង។ នីតិវិធីមានការស្មុកស្មាញ គួរតែកំណត់ឱ្យច្បាស់ថាប្រ/ព ធ្លាប់បោះនៅកន្លែងណាឱ្យគាត់បោះនៅកន្លែងនោះដដែល។ គួររក្សាទំរង់១០១៨ សំរាប់អ្នកបាត់បង់ឯកសារពិតប្រាកដ។ មិនគាំទ្រការធ្វើប្រតិភូកម្មការចុះឈ្មោះឱ្យទៅស្មៀន គួរឱ្យទៅ គ.ជ.ប ដូចឆ្នាំ១៩៩៨ រីឯការលប់ឈ្មោះ គ.ជ.ប គួតែមានលិខិតស្នាមច្បាស់លាស់ទើបអាចលប់ចេញពីបញ្ជីឈ្មោះបាន។ គួរយកតាមសមភាពក្នុងការប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត និងគាំទ្រឱ្យមានក្រុមប្រឹក្សាឯករាជ្យចំរុះគ្រប់គ្រងការចាក់ផ្សាយ។ គាំទ្រចំពោះដំណើរការរបណ្តឹងពីឃុំ រហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញ តែទោះបីបណ្តឹងតាមទូរស័ព្ទ ឬតាមមាត់ក៏ត្រូវចុះស៊ើបអង្កេតដែរ ឬត្រូវបង្កើតគណៈកម្មការឯករាជ្យចំរុះដែលមានអន្តរជាតិជាប្រធាន។ គាំទ្រឱ្យមានការកំណត់ និងបង្ហាញប្រភពមូលនិធិគណបក្ស ឬបេក្ខជនជាសាធារណៈ និងគាំទ្រឱ្យមានច្បាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយ។ ការយល់ដឹងរបស់អ្នកបោះឆ្នោតនៅមានកំរិត សូមឱ្យអង្គការសង្គម ជាពិសេស ខុមហ្រ្វែលជួយបន្ថែមទៀត។ ប្រជាធិបតេយ្យ មិន ពេញចិត្តទៅលើស្ថានភាពនៃសេរីភាពបញ្ចេញមតិ សេរីភាពទទួលពត៌មាន និងសេរីភាពប្រមូលផ្តុំនៅពេលបច្ចុប្បន្ននេះទេគឺត្រូវតែកែលំអរ។ ឯកភាពទាំងស្រុងលើគំរូរៀបចំវេទិកា និងត្រៀមសហការណ៍ចូលរួម។

បញ្ហាអទិ្ទភាព៥មានៈ ប្រព័ន្ធផ្សព្វផ្សាយ ការចុះឈ្មោះបោះឆ្នោត ហិរញ្ញ វត្ថុនយោបាយ សេរីភាពប្រមូលផ្តុំ និងសេរីភាពបញ្ចេញមតិ។

### 2.1.6. គណបក្សសិទ្ធិមនុស្ស

ចង់បានការបោះឆ្នោតតាមប្រព័ន្ធឯកត្តនាម គាំទ្រការកំណត់កូតាស្រ្តី៣០%ក្នុងសភាជាតិ។ ចង់ឱ្យសង្គមស៊ីវិលរៀបចំការបោះឆ្នោត ឬឱ្យមានសមភាពតំណាងពីថ្នាក់លើរហូតដល់ក្រោម។ គ.ជ.ប គួរចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងគួរមានច្បាប់ដាក់ទោសដល់មន្រ្តីរដ្ឋាភិបាលដែល ល្មើសច្បាប់បោះឆ្នោត និងគួរមានគណៈកម្មការចំរុះដោយមានសង្គមស៊ីវិលជ្រើសរើសអជ្ញាធរបោះឆ្នោតតាំងពីលើដល់ក្រោម។ សុំឱ្យយកនីតិវិធី បោះឆ្នោតដូចអ៊ុនតាក់។ ត្រូវបញ្ឈប់ប្រើទំរង់១០១៨ ហើយប្រគល់ការចុះឈ្មោះនេះទៅ គ.ជ.ប ដោយមានសង្គមស៊ីវិលសង្កេតការណ៍។ រីឯការលប់ឈ្មោះត្រូវមានការឯកភាពពីគណៈកម្មការបោះឆ្នោត សង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ សង្កាត់ ហើយពេលចុះឈ្មោះសុំឱ្យមេភូមិ ប្រកាសប្រាប់ប្រជាពលរដ្ឋ និងបិទបញ្ជីឈ្មោះនៅតាមភូមិ។

សុំឱ្យមានតែកម្មវិធីសមភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត និងគាំទ្រឱ្យមានក្រុមប្រឹក្សាចាក់ផ្សាយដែលមានសង្គមស៊ីវិលចូលរួម។ ការដោះស្រាយបណ្តឹងត្រូវតែមានតុលាការមួយឯករាជ្យចេញពីគ.ជ.ប ដែលមានការចូលរួមពីសង្គមស៊ីវិលដែរ។ គាំទ្រឱ្យមានការកំណត់ និងបង្ហាញមូលនិធិគណបក្ស ឬបេក្ខជន ស្ថិតក្រោមច្បាប់គ្រប់គ្រង មួយច្បាស់លាស់។ គួរតែបន្តការអប់រំអ្នកបោះឆ្នោតជាពិសេសអំពីតំលៃនៃសន្លឹកឆ្នោត។ ចំពោះប្រជាធិតេយ្យ

គឺមិនមានការពេញចិត្តឡើយ គួរតែត្រូវបានកែលំអរឡើងវិញ និងឯកភាពចាត់ទុកច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានជាអទិ្ទភាពក្នុងអណតិទី៤នេះ។ ឯកភាពតាំងស្រុងលើគំរូរៀបចំវេទិកា និងត្រៀមសហការណ៍ចូលរួម។

បញ្ហាអទិ្ទភាព៥មានៈ សមាសភាព គ.ជ.ប ការចុះឈ្មោះបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយ សេរីភាពប្រមូល ផ្តុំ និងសេរីភាពបញ្ចេញមតិ។

### 2.1.7. គណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោត

ប្រព័ន្ធសមាមាត្រល្អសំរាប់កម្ពុជាបច្ចុប្បន្ន តែវាអាស្រ័យទៅលើច្បាប់កំណត់ ហើយត្រូវតែកំណត់ក្នុងច្បាប់អំពីការចូលរួមរបស់ស្ត្រីឱ្យបានកំរិតច្រើន។ អាចទទួលយកបានចំពោះ គ.ជ.ប សព្វថ្ងៃ សមាសភាពគួរយកតាមច្បាប់កំណត់ តែគួពង្រឹងកែលំអរច្បាប់បន្ថែមទៀត។ មិនគួរឱ្យមានការកំណត់ស្តងជាចំពោះអង្គាធរបោះឆ្នោតថ្នាក់ក្រោមទេ តែយើងរើសទៅតាមកន្លែងណាហើយកំណត់យកកំរិតណា។ គួររក្សាទុក ទំរង់១០១៨ តែពង្រឹងនីតិវិធី និងពង្រឹងការងារស្មៀនឡើងវិញ។ ការលប់ឈ្មោះនៅរក្សាទំរង់១០២៥ដដែល តែត្រូវមានការ យោងលិខិតពាក់ព័ន្ធមកប្រើប្រាស់។ ការផ្សព្វផ្សាយគួប្រើកម្មវិធីសមភាព និងឯកភាពបង្កើតក្រុមប្រឹក្សាចំរុះសំរាប់ការចាក់ផ្សាយ តែត្រូវមានអ្នកសំរបសំរួល។ ចំពោះដំណើរការបណ្តឹងទទួលយកបានតែគួតែមានការដោះស្រាយបណ្តឹងតាមទូរស័ព្ទ ឬផ្ទាល់មាត់។ គួរតែមានការកំណត់ និងបង្ហាញពីប្រភពមូលនីធិគណបក្ស ឬបេក្ខជនគណបក្សនយោបាយជាសាធារណៈ ហើយករណីនេះគួរតែដាក់ចូលក្នុងច្បាប់បោះឆ្នោត និងគួរមានក្រុមសោវនកម្មឯករាជ្យ និងគួរតែបន្តការអប់រំអ្នកបោះឆ្នោតជាពិសេសលើសិទ្ធិធ្វើនយោបាយ និងនីតិវិធីបោះឆ្នោត។ ប្រជាធិបតេយ្យ សេរីភាពបញ្ចេញមតិសមល្មម តែគួរមានការចាក់ផ្សាយកំនិតប្រឆាំងតាមវិទ្យុ និងទូរទស្សន៍។ សេរីភាពទទួលព័ត៌មាន ទទួលយកបាន តែគាំទ្រឱ្យមានច្បាប់ស្តីពី សិទ្ធិទទួលបានព័ត៌មានបានឆាប់កាន់តែប្រសើរ។ សេរីភាពប្រមូលផ្តុំនៅមានកំរិត គួរមានការកែលំអរ ឱ្យបានច្បាស់លាស់ជាងមុន។ ឯកភាពតាំងស្រុង លើគំរូរៀបចំ វេទិកា និងត្រៀមសហការណ៍ចូលរួម។

បញ្ហាអទិ្ទភាព៥មានៈ ការចុះឈ្មោះ បោះឆ្នោត ការដោះស្រាយបណ្តឹង ប្រព័ន្ធផ្សព្វផ្សាយ សេរីភាពបញ្ចេញមតិ និងសេរីភាពប្រមូលផ្តុំ។

### 2.1.8. គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត

ប្រព័ន្ធសមាមាត្រសមរម្យគួររក្សាឱ្យនៅដដែល និងគួរមានចែងក្នុងច្បាប់ក្នុងការលើកស្ទួយស្ត្រីឱ្យបានច្បាស់លាស់។ អង្គាធររៀបដែលរៀបចំការបោះឆ្នោត ចង់ឱ្យមានសមភាពតំណាងពីលើដល់ក្រោម។ គួររក្សាទុកទំរង់១០១៨ តែការចុះឈ្មោះគួប្រគល់ឱ្យ គ.ជ.ប ជាអ្នកធ្វើវិញរីឯការលប់ឈ្មោះតាមទំរង់ ១០២៥ មុននឹងលប់ត្រូវមានការសួនាំ និងលិខិតស្នាមច្បាស់លាស់។ ប្រព័ន្ធផ្សព្វផ្សាយគួធ្វើតាមកម្មវិធីសមភាពបានហើយ និងឯកភាពឱ្យមានបង្កើតក្រុមប្រឹក្សាចាក់ផ្សាយឯករាជ្យមួយ។ ឯកភាពលើដំណើរការបណ្តឹងកន្លងមក។គ្មានយោបល់ចំពោះបញ្ហាហិរញ្ញវត្ថុ

នយោបាយ គឺអាស្រ័យលើច្បាប់។ សុំឱ្យមានការអប់រំអ្នកបោះឆ្នោតបន្តទៀតជុំវិញនីតិវិធីបោះឆ្នោត។ ប្រជាធិបតេយ្យ សេរីភាពបញ្ចេញមតិ និងសេរីភាពទទួលព័ត៌មានអាចទទួលយកបាន រីឯសេរីភាពប្រមូលផ្តុំគ្មានយោបល់។ ឯកភាពតាំងស្រុង លើគំរូរៀបចំវេទិកា និងត្រៀមសហការណ៍ចូលរួមតែសូមជូនព័ត៌មានឱ្យបានមុនយ៉ាងហោចណាស់ ១សប្តាហ៍មុនថ្ងៃវេទិកាព្រោះសុទ្ធតែជាគ្រូបង្រៀន។

បញ្ហាអទិ្ទភាព៥មានៈប្រព័ន្ធបោះឆ្នោតសមាសភាព គ.ជ.ប ប្រព័ន្ធផ្សព្វផ្សាយ សេរីភាពប្រមូលផ្តុំនិងសេរីភាពបញ្ចេញមតិ។

### 2.1.9. ស្មៀនឃុំ

គួរយកប្រព័ន្ធសមាមាត្រ និងរូបមន្តគណនាអសនៈដូចសព្វថ្ងៃ និងគាំទ្រក្នុងការលើកស្ទួយស្ត្រី។ គ.ជ.ប អាចទទួលយកបានទាំងអស់។ ការចុះឈ្មោះគួរជំរុញការចេញអត្តសញ្ញាណប័ណ្ណ ហើយលប់ចោលទំរង់១០១៨។ចំណែកការលប់ឈ្មោះក្នុងទំរង់១០២៥ត្រូវមានឯកសារ បញ្ជាក់ច្បាស់លាស់ពីមេភូមិ ហើយគួរតែមានការចុះហត្ថលេខាពីភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍ជាតិ។ ការប្រើប្រាស់ប្រព័ន្ធ ផ្សព្វផ្សាយអាចទទួលយកបាន។ រីឯការដោះស្រាយបណ្តឹងក៏សមស្រប។ ចំណែកហិរញ្ញវត្ថុនយោបាយគួរធ្វើដូចកន្លងមកគឺទៅតាម ធនធានរបស់គេទៅតែបើតំរូវឱ្យប្រកាសប្រភពមូលនីធិ ឬទ្រព្យសម្បត្តិគួរប្រកាសជាសាធារណៈ។ មិនចាំបាច់មានការអប់រំអ្នកបោះឆ្នោត ទៀតទេ។ ប្រជាធិបាតយ្យ សេរីភាពទាំងបីអាចទទួលយកបាន ហើយការបញ្ចេញមតិបែប បរិហាកេរ៍ ឬផ្សព្វផ្សាយពត៌មាន មិនពិតគួរតែមានទោស។ ឯកភាពតាំងស្រុង លើគំរូរៀបចំវេទិកា និងត្រៀម សហការណ៍ចូលរួម។ បញ្ហាអទិ្ទភាព៥មានៈការចុះឈ្មោះបោះឆ្នោត ហិរញ្ញវត្ថុនយោបាយ សមាសភាព គ.ជ.ប សេរីភាពប្រមូលផ្តុំ និងសេរីភាពបញ្ចេញមតិ។

### 2.1.10. អង្គការក្រៅរដ្ឋាភិបាល

គាំទ្រប្រព័ន្ធសមាមាត្រតែយកការគណនាអសនៈតាមរូបមន្តអ៊ុនតាក់ និងឯកភាពក្នុងការកំណត់កូតាស្ត្រី៣០% នៅក្នុងច្បាប់។ ចំពោះ គ.ជ.ប ចង់ឱ្យមានតុល្យភាពតំណាងតាំងពីលើរហូតដល់ក្រោម និងស្ថាប័ននេះត្រូវចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ សមាសភាពរបស់មន្ត្រីរៀបចំការបោះឆ្នោតត្រូវរើសក្រៅពីមន្ត្រីរាជការ និងយកកំរិតត្រឹមមធ្យមសិក្សា។ នីតិវិធីបោះឆ្នោតគួរយកតាមអ៊ុនតាក់។ ត្រូវលប់ចោលទំរង់ ១០១៨ ដោយជំរុញការធ្វើអត្តសញ្ញាណប័ណ្ណឱ្យបានទាន់ពេល និងតំរូវឱ្យការពារឱ្យបានគង់វង់។ ការចុះឈ្មោះបោះឆ្នោតត្រូវប្រគល់ឱ្យ គ.ជ.ប វិញហើយការលប់ឈ្មោះត្រូវមានឯកសារបញ្ជាក់ច្បាស់លាស់។ គួរប្រើកម្មវិធីសមភាពសំរាប់ការ ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលបោះឆ្នោត។ មិនពេញចិត្តចំពោះដំណើរការបណ្តឹងបោះឆ្នោត។ មិនគាំទ្រក្នុងការកំណត់ ការចំណាយរបស់គណបក្ស ឬបេក្ខជនទេ តែត្រូវតែបង្ហាញប្រភពមូលនីធិ។ ត្រូវតែបន្តអប់រំការបោះឆ្នោត។ ប្រជាធិបតេយ្យ សេរីភាពក្នុងការ

បញ្ចេញមតិនៅមានកំរិត ត្រូវកែលំអរឡើងវិញ ហើយមិនគាំទ្រចំពោះមតិដែលសុំឱ្យដាក់បទបរិហាកេរ៍ ឬផ្សាយ ព័ត៌មានមិនពិតជាទោសឧក្រិដ្ឋ។ ឯកភាពឱ្យមានការចាក់ផ្សាយមតិប្រឆាំងតាមវិទ្យុ និងទូរទស្សន៍ តែគួរកុំយកទៅឃោសនាពេលបោះឆ្នោត។ សេរីភាពទទួលបានព័ត៌មាន មិនទាន់បានទូលាយរហូតដល់មូលដ្ឋានទេ។ឯកភាពចំពោះច្បាប់ស្តីពីសិទ្ធិទទួល បានព័ត៌មានជា អទ្ធិភាពសំរាប់អណតិទី៤នេះ។ ចំពោះសេរីភាពប្រមូលផ្តុំមិនពេញចិត្តទេ។ ឯកភាពតាំងស្រុង លើគំរូរៀបចំវេទិកា និងត្រៀម សហការណ៍ចូលរួម។ បញ្ហាអទ្ធិភាព៥មានៈការចុះឈ្មោះ បោះឆ្នោត ហិរញ្ញវត្ថុនយោបាយ សមាសភាព គ.ជ.ប សេរីភាពប្រមូលផ្តុំ និងសេរីភាពបញ្ចេញមតិ។

**2.1.11. ក្រុមប្រឹក្សាខេត្ត/ក្រុង**

គាំទ្រយកប្រព័ន្ធសមាមាត្រដូចកន្លងមក និងគាំទ្រឱ្យមានការលើកស្ទួយស្ត្រីក្នុងអ្នកដឹកនាំឱ្យបានច្រើន និងពង្រីកជាបណ្តើរៗ។ គ.ជ.ប គួរបន្តដូចសព្វថ្ងៃទាំងអស់។ មិនអាចបោះបង់ទំរង់ ១០១៨ បានទេ វាជាការកាត់បន្ថយទំនាស់បាន ឯការចុះឈ្មោះគួរនៅដដែល។ ការលប់ឈ្មោះគួររក្សាក្នុងទំរង់១០២៥ដដែលតែគួរពង្រឹងការអនុវត្តរបស់មូលដ្ឋាន។ ចំពោះប្រព័ន្ធផ្សព្វភសាយល្អហើយ។ ចំណែកដំណើរ ការបណ្តឹងត្រឹមត្រូវហើយ។ មិនមានការចង្អៀតចង្អល់ទេចំពោះការកំណត់ ឬប្រកាសប្រគពមូលនីធិគណបក្ស ឬបេក្ខជនគណបក្សនយោបាយ។ ការអប់រំអ្នកបោះឆ្នោតនៅតែបន្តជាការល្អ។ ប្រជាធិបតេយ្យ ពេញចិត្តទាំងអស់ តែបើមានបញ្ហាគួរលើកយកមកឱ្យមេៗ ដោះស្រាយដដែកគ្នានៅលើតុទៅ។ ចំពោះគំរូរៀបចំវេទិកា មិនមានជំទាស់វិញទេ តែបានសំដែងការមិនពេញចិត្តចំពោះការឱ្យពិន្ទុក្នុងវេទិ កាម្ចាស់ឆ្នោតកន្លងមកហើយត្រៀមសហការណ៍ចូលរួម តែសំណូមពរធ្វើលិខិតស្នាមទៅអភិបាលខេត្តបញ្ជាក់ពីគោលបំណងឱ្យបានច្បាស់លាស់។

បញ្ហាអទ្ធិភាព៥មានៈ បញ្ជីឈ្មោះ ប្រព័ន្ធផ្សព្វផ្សាយ ដោះស្រាយបណ្តឹងបោះឆ្នោត សេរីភាពទទួលពត៌មាន និងសេរីភាពបញ្ចេញមតិ។

**2.1.12. សាធារណៈជន**

សុំឱ្យយកប្រព័ន្ធឯកត្តនាម មិនពេញចិត្តការគណនាអសនៈដូចកន្លងមកទេ។គាំទ្រឱ្យមានការកំណត់កូតាស្ត្រី៣០% នៅក្នុងច្បាប់។ សមាសភាព គ.ជ.ប សុំឱ្យមានស្មើភាពគ្នាពីលើដល់ក្រោម និងចង់ឱ្យមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ ត្រូវមានច្បាប់ដាក់ទោសដល់ មន្ត្រីរាជការដែលល្មើសច្បាប់បោះឆ្នោត។ គួរលប់បំបាត់ការប្រើទំរង់ ១០១៨ ដោយជំរុញការធ្វើអត្តសញ្ញាណប័ណ្ណ ឬការចុះឈ្មោះយកដូចកាលពីឆ្នាំ១៩៩៨។ ចំពោះការលប់ឈ្មោះត្រូវមានឯកសារបញ្ជាក់គ្រប់គ្រាន់មុនលប់។ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយត្រូវធ្វើតាមកម្មវិធីសមភាព។ ត្រូវមានការកែលំអរដំណើរការបណ្តឹង និងពង្រឹងការអនុវត្តតាមច្បាប់ឱ្យបានតឹងរឹង។ គាំទ្រឱ្យមានការកំណត់ការចាយវាយរបស់គណបក្ស ឬបេក្ខជនក្នុងពេលឃោសនាឱ្យបានសមរម្យ តែមិនបាច់

បង្ហាញពីប្រភពមូលនីធីទេ។បន្តការអប់រំអ្នកបោះឆ្នោតពីសិទ្ធិ និងកាតព្វកិច្ច និងតំលៃនៃសន្លឹកឆ្នោត។ ប្រជាធិបតេយ្យ សេរីភាពបញ្ចេញមតិ គួរតែមានការកែលំអរទៅតាមច្បាប់រដ្ឋធម្មនុញ្ញ។ យល់ព្រម នូវយោបល់សុំឱ្យ កុំចាត់ជាបទឧក្រិដ្ឋចំពោះបទបរិហាកេរិ៍ ឬផ្សាយព័ត៌មានមិនពិត។ ឯកភាពចាត់ជាអទិ្ទភាពក្នុងអណតិទី៤ ឱ្យបានច្បាប់ស្តីពីសេរីភាពទទួលព័ត៌មាន។ សេរីភាពបញ្ចេញមតិ គឺចង់បានតាមស្តង់ដាអន្តរជាតិ។ ឯកភាពតាំងស្រុងលើគំរូរៀបចំ វេទិកា និងត្រៀមសហការណ៍ចូលរួម។

បញ្ហាអទិ្ទភាព៥មានៈ សមាសភាព គ.ជ.ប ប្រព័ន្ធផ្សព្វផ្សាយ ការអប់រំអ្នកបោះឆ្នោតសេរីភាពប្រមូល ផ្តុំ និងសេរីភាពបញ្ចេញមតិ។

### ២.៣ ខេត្តមណ្ឌលគិរី

**របាយការណ៍នៃកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់ខេត្តមណ្ឌលគិរី**

1. **ពេលវេលានៃសកម្មភាពនៃការជួបប្រជុំពិភាក្សា**

| ក្រុមដែលបានជួបពិភាក្សា | ទីកន្លែងពិភាក្សា | កាលបរិច្ឆេទ | រយពេល | សមាសភាពក្រុមជួបពិភាក្សា | សមាសភាព |
|---|---|---|---|---|---|
| គណបក្សប្រជាជនកម្ពុជា | | | | សមាសភាពតែមួយ ជាមួយក្រុមប្រឹក្សាខេត្ត | |
| គណបក្សសមរង្ស៊ី | ទីស្នាក់ការអាដហុក | ០៩ កញ្ញា ២០១០ | ២ម៉ោង | លោកសេង លី(តំណាងគណបក្សខេត្ត) លោកសាន់ តឹង (សកម្មជន) | លោកស៊ិន ទិត្យសីហា លោក លឹម ម៉ុន (លេខា) អ្នកស្រី កែវ ជីវ៉េ |
| គណបក្សហ្វុនស៊ិនប៊ិច | ទីស្នាក់ការគណបក្ស | ០៨ កញ្ញា ២០១០ | ២ ម៉ោង | លោក ខឹម ផា (អនុប្រធានគណបក្ស) លោក ទៀវ ឡាំផា (ប្រធានគណបក្សក្រុងសែនមនោរម្យ) លោក ឡុង សុធី | លោកស៊ិន ទិត្យសីហា លោក លឹម ម៉ុន (លេខា) អ្នកស្រី កែវ ជីវ៉េ |

| | | | | | |
|---|---|---|---|---|---|
| | | | | (ប្រធានប្រតិបត្តិស្រុកកែវសីមា)<br><br>លោក ឈុំ ផន (ប្រធានទទួលបន្ទុកការបោះឆ្នោត)<br><br>លោក ផៃ ដា (ប្រធានសន្តិសុខគណបក្ស) | |
| គណបក្សជាតិនិយម | ទីស្នាក់ការគណបក្ស | ០៧ កញ្ញា ២០១០ | ២ ម៉ោង | លោក ទិទ្ធ សុផុន (ប្រធានគណបក្សខេត្ត) | លោកស៊ិន ទិត្យសីហា<br>លោក លឹម ម៉ុន (លេខា)<br>អ្នកស្រី កែវ ដឺរ៉េ |
| គណបក្សសិទ្ធិមនុស្ស | មិនមានស្នាក់ការ និងតំណាងនៅក្នុងខេត្តមណ្ឌលគិរីនេះទេ | | | | |
| គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត | ស្នាក់ការលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត | ០៦ កញ្ញា ២០១០ | ២ ម៉ោង | លោក ទី ឈឿន (ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តមណ្ឌលគិរី)<br><br>លោក យ៉ន សុខុម (អនុប្រធានលេខាធិការដ្ឋានរៀបចំការបោះ ឆ្នោតខេត្តមណ្ឌលគិរី) | លោកស៊ិន ទិត្យសីហា<br>លោក លឹម ម៉ុន (លេខា)<br>អ្នកស្រី កែវ ដឺរ៉េ |

| | | | | | |
|---|---|---|---|---|---|
| គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត | មន្ទីរកសិកម្មខេត្ត | ០៧ កញ្ញា ២០១០ | ២ ម៉ោង | លោក អ៊ឹម ចាន់ណា (អតីតប្រធានគណៈកម្មការសង្កាត់សុខដុម រៀបចំការបោះឆ្នោត)<br>អ្នកស្រី វ៉ែន សុភារម្យ (អតីតអនុប្រធានគណៈកម្មការសង្កាត់សុខដុម រៀបចំការបោះឆ្នោត) | លោកស៊ិន ទិត្យសីហា<br>លោក លឹម ម៉ុន (លេខា)<br>អ្នកស្រី កែវ ដឹរ៉េ |
| ស្មៀនឃុំ | ទីស្នាក់ការអោដហុក | ០៧ កញ្ញា ២០១០ | ២ ម៉ោង | លោក ជ្រេង ធីល ស្មៀនសង្កាត់រមនា<br>លោក យន អួន ស្មៀនសង្កាត់ស្លានមានជ័យ<br>អ្នកស្រី ហង់ សាម៉ែ ស្មៀនសង្កាត់សុខដុម | លោកស៊ិន ទិត្យសីហា<br>លោក លឹម ម៉ុន (លេខា)<br>អ្នកស្រី កែវ ដឹរ៉េ |
| អង្គការក្រៅរដ្ឋាភិបាល | ទីស្នាក់ការអោដហុក | ០៦ កញ្ញា ២០១០ | ២ ម៉ោង | លោក កែវ សារ៉េត (អុកស្វាមអូស្ត្រាលី Oxfam Autralia)<br>លោក ញាណ សុផូ (អង្គការភូមិខ្ញុំ MVI)<br>លោក ឈឹម សាខន (អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច | លោកស៊ិន ទិត្យសីហា<br>លោក លឹម ម៉ុន (លេខា)<br>អ្នកស្រី កែវ ដឹរ៉េ |

| | | | | | |
|---|---|---|---|---|---|
| | | | | ICSO )<br><br>លោក សម សារិន (ADHOC)<br><br>លោក គល់ មីឌី (ADHOC)<br><br>លោក ហេង ប៊ុនធឿន (អង្គការអភិវឌ្ឍន៍ និងភាគជាដៃគូរក្នុង<br><br>សកម្មភាព DPA) | |
| ក្រុមប្រឹក្សាខេត្ត/ក្រុង | ទីស្តីការសាលាខេត្ត | ០៧ កញ្ញា ២០១០ | ២ ម៉ោង | ឯកឧត្តម ម៉ែន ង៉ុយ សមាជិកក្រុមប្រឹក្សាខេត្ត និងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា<br><br>ឯកឧត្តម ញ៉ា រ៉ាងចាន់ សមាជិកក្រុមប្រឹក្សាខេត្ត និងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា | លោកស៊ិន ទិត្យសីហា<br>លោក លឹម ម៉ុន (លេខា)<br>អ្នកស្រី កែវ ដឹរ៉េ |
| សាធារណៈជន | ទីស្នាក់ការបណ្តាញអង្គការក្រៅរដ្ឋាភិបាល | ០៨ កញ្ញា ២០១០ | ២ ម៉ោង | អ្នកស្រី គឹម រតនា<br><br>អ្នកស្រី ប៊ូ សារឿន<br><br>លោក អ៊ុំ ជោគសក្តា | លោកស៊ិន ទិត្យសីហា<br>លោក លឹម ម៉ុន (លេខា)<br>អ្នកស្រី កែវ ដឹរ៉េ |

| | | | | | |
|---|---|---|---|---|---|
| | | | | លោក សឹក ស្រាយ<br>លោក ភុំ សារិត<br>អ្នកស្រី មួន សុភាង<br>អ្នកស្រី ជឿន សារ៉េត<br>អ្នកស្រី គឹម សារ៉ន | |

## 2. បញ្ហាដែលបានរកឃើញក្នុងអំឡុងពេលពិភាក្សារ

### 2.1. បញ្ហាដែលក្រុមនិមួយៗបានលើកឡើង

#### 2.1.1. គណបក្សប្រជាជនកម្ពុជា

បានជួបពិភាក្សានិងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្ត និងជាតំណាងឱ្យគណ បក្សប្រជាជនកម្ពុជាផងដែរ។

#### 2.1.2. គណបក្សសមរង្ស៊ី

ក្នុងជំនួបពិគ្រោះយោបល់ជាមួយតំណាងគណបក្សសមរង្ស៊ី ត្រង់ចំណុចកំណែ ទម្រង់ការបោះឆ្នោត លោក បានស្នើឱ្យមានការអនុវត្តតាមប្រព័ន្ធឯកត្តនាម ពីព្រោះបេក្ខជនមិននៅក្រោមគំនៀបគណបក្សនយោបាយ និងមិនមានបក្សពួកនិយម។ លោកបានគាំទ្រឱ្យមានការកំណត់ឱ្យមានស្ត្រីចូលរួមឱ្យបានច្រើន។ ចំពោះមន្ត្រីរៀប ចំការបោះឆ្នោតលោកបានសង្កត់ធ្ងន់ថាមានភាពលំអៀងក្នុងការអនុវត្តន៍ការងារកន្លងមក ហើយបានស្នើឱ្យ អង្គការសង្គមស៊ីវិលជាអ្នកជ្រើសរើសមន្ត្រីរៀបចំការបោះឆ្នោតឃុំ/សង្កាត់ និងការិយាល័យ។ ជុំវិញបញ្ហា ទាក់ទងការចុះឈ្មោះ លោកបានលើកឡើងថាកន្លងមកមានការបាត់ឈ្មោះ និងការផ្លាស់ប្តូរការិយាល័យអ្ នកបោះឆ្នោត។ ចំពោះឯកសារបញ្ជាក់អត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ) នៅមានការខ្វះខាត ហើយទម្រង់ បែបបទ ១០១៨ គួរតែបន្តប្រើប្រាស់តែគណៈកម្មាធិការឃុំរៀបចំការបោះឆ្នោតជាអ្នកចេញ និងមានការត្រួតពិនិត្យដោយអង្គការសង្គមស៊ីវិល។ ការចុះឈ្មោះគួរតែ គ .ជ.ប ចាត់មន្ត្រីរបស់ ខ្លួន

មកធ្វើការជំនួសស្មៀនវិញ និងឱ្យមានការចុះឈ្មោះ និងបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតាមភូមិ។ លើការដោះស្រាយបណ្ដឹងកន្លង មក មិនទាន់បានល្អប្រសើរនៅឡើយ ហើយគួរតែបង្កើតគណៈកម្មាធិការឯករាជ្យមួយ ដើម្បីដោះ ស្រាយបញ្ហានេះ។ ចំពោះហិរញ្ញវត្ថុគណបក្សនយោបាយគួរតែមានកំណត់ចំណាយរបស់គនបក្សនីមួយៗក្នុងកំឡុងពេលបោះឆ្នោត និងដោយឡែកអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកំរិតទាប ហើយគួរតែផ្សព្វផ្សាយបន្ថែម ទៅដល់តាមភូមិ។

ប្រជាពលរដ្ឋមិនទាន់មានសេរីភាពគ្រប់គ្រាន់នៅឡើយក្នុងការបញ្ចេញមតិ ទទួលព័ត៌មានប្រមូលផ្ដុំ និងបានសំណូមពរឱ្យអាជ្ញាធរបើទូលាយចំពោះបញ្ហាទាំងនេះ។

### 2.1.3. គណបក្សហ៊្វុនស៊ិនប៉ិច

ក្នុងកិច្ចពិគ្រោះយោបល់តំណាងគណបក្សបានបង្ហាញពីការគាំទ្រប្រព័ន្ធបោះឆ្នោតសមាមាត្រ និងការកំណត់កូតាស្ត្រីឱ្យបាន៣០%។ ចំពោះសមាជិក គ .ជ.ប តំណាងគណបក្សបានស្នើសុំឱ្យមាន ការជ្រើស រើសដោយគណៈកម្មការចំរុះដោយឡែង ដែលមិនចំណុះរដ្ឋាភិបាល ជា ពិសេសក្រសួងមហាផ្ទៃ ហើយគួរតែមានការ កំណត់អណត្តិសមាជិក គ.ជ.ប និងធ្វើការដោះដូរបើសមាជិក ណាមួយអនុវត្តន៍មិនត្រឹមត្រូវ។ ចំពោះនីតិវិធី គ .ជ.ប ឃើញថាបានល្អហើយ ប៉ុន្តែមន្ត្រី អនុវត្តន៍មួយចំនួនធ្វើមិនទាន់បានល្អនៅឡើយ ព្រោះមានការប្រកាន់បក្សពួក។

ចំណែកឯឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ប្រើក្នុងការបោះឆ្នោតនៅមានការខ្វះខាត ជាពិសេសអត្តសញ្ញាណប័ណ្ណ ព្រោះមានការយកលុយពីប្រជាពលរដ្ឋ ដែលនាំឱ្យពយកគាត់មិនទៅធ្វើដូច្នោះគួរតែបន្តប្រើប្រាស់ទម្រង់១០១៨ ប៉ុន្តែត្រូវចេញដោយ គឃ /សប (CEC) ។ ចំពោះការចុះឈ្មោះគួរតែ គ .ជ.ប ចាត់មន្ត្រី របស់ខ្លួនឱ្យចូលរួមសហការជាមួយស្មៀន ដើម្បីឱ្យមានការត្រួតពិនិត្យគ្រប់គ្រាន់។ អង្គការក្រៅរដ្ឋាភិ បាលគួរតែជំរុញឱ្យមន្ត្រីរៀបចំការបោះឆ្នោតជានាឈ្មោះប្រជាពលរដ្ឋក្នុងការចុះឈ្មោះ និងការលុបឈ្មោះ មិនមែន ប្រជាពលរដ្ឋខ្លួនឯងជាធានានោះទេ។

ចំពោះការបែងចែកពេលវេលាផ្សព្វផ្សាយរបស់គណបក្សនយោបាយ ដែលមានអាសនៈច្រើនមានពេលច្រើន អាសនៈតិចមានពេលតិច គឺមិនយុត្តិធម៌ទេ ត្រូវតែមានការបែងចែកឱ្យបានស្មើគ្នា និង បើកឱ្យទូលាយ កុំឱ្យមានការរិតត្បិត។ គួរតែមានបង្កើតគណៈកម្មការដោយមួយ ដែល មានសមាសភាពពីអង្គការជាតិ និងអន្តរជាតិ ជាអ្នកដោះស្រាយវិវាទក្នុងការបោះឆ្នោត។

ចំពោះហិរញ្ញវត្ថុគណបក្សនយោបាយគួរតែមានការកំណត់ចំណាយរបស់គនបក្សនីមួយៗពេលបោះឆ្នោត។ ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកំរិត ដូច្នោះគួរតែសង្គមស៊ីវិលជួយធ្វើការផ្សព្វផ្សាយបន្ថែមទៀត។

ប្រជាពលរដ្ឋមិនទាន់មានសេរីភាពទូលំទូលាយក្នុងការសំដែងមតិ និងទទួលព័ត៌មាន និង ម៉្យាងទៀតគួរតែកុំឱ្យជាប់ពន្ធនាគារលើបទផ្សព្វផ្សាយព័ត៌មានមិនពិត និងបរិហាកេរ្តិ៍ គ្រាន់តែមានការ ពិន័យជាប្រាក់ និងការកែតំរូវព័ត៌មាននោះឡើងវិញបានហើយ។

### 2.1.4. គណបក្សជាតិនិយម

ក្នុងកិច្ចពិគ្រោះយោបល់តំណាងគណបក្ស បានបង្ហាញពីការគាំទ្រប្រព័ន្ធបោះឆ្នោតសមាមាត្រ និងការកំណត់កូតាស្ត្រីចូលរួមឱ្យបានច្រើន។

ចំពោះសមាជិកគណៈកម្មាធិការរៀបចំការបោះឆ្នោតថ្នាក់ជាតិ មិនមានបញ្ហាទេ ប៉ុន្តែនៅថ្នាក់ខេត្ត និងឃុំនៅមានភាពលំអៀងក្នុងការអនុវត្តតួនាទីរបស់ខ្លួ នក្នុងរយៈកាលកន្លងមក និងគួរតែមានការកំណត់អណត្តិសមាជិក គ .ជ.ប។ ចំពោះឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រជាពលរដ្ឋសម្រាប់ប្រើក្នុងការបោះឆ្នោតនៅមានបញ្ហាខ្វះខាតនៅឡើយ ដូច្នោះគួរបន្តប្រើប្រាស់ទម្រង់ ១០១៨ ។ កន្លងមកការ ប្រតិភូកម្មអំណាចឱ្យស្មៀនក្នុងការចុះឈ្មោះបោះឆ្នោត បានបង្កឱ្យមានបញ្ហាខុសឈ្មោះអ្នកបោះឆ្នោត ដូចនេះគួរ តែ គ .ជ.ប ចាត់មន្ត្រីរបស់ខ្លួនឱ្យមកសហការធ្វើការងារជាមួយស្មៀន និងគួរមានការបិទ ឈ្មោះអ្នកបោះឆ្នោតនៅតាមភូមិ ហើយមេភូមិ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ គួរតែមានតុលាការបោះ ឆ្នោតសម្រាប់ធ្វើការដោះស្រាយវិវាទបោះឆ្នោតនៅតាមខេត្តនីមួយៗ។ ហរិញ្ញវត្ថុគណបក្សនយោបាយ គួរតែមានការកំណត់ការចាយវាយក្នុងពេលបោះឆ្នោត។ ចំពោះការយល់ដឹងរបស់ប្រជាពលរដ្ឋ ជាពិសេសមនុស្សមានវ័យចាស់ នៅមានកំរិត និងមិនសូវមានការចាប់អារម្មណ៍ក្នុង ដំណើរការបោះឆ្នោត ដូចនេះគួរតែគណបក្សនីមួយៗបង្កើនការផ្សព្វផ្សាយបន្ថែមទៀត។

ការបញ្ចេញមតិនៅមានការខ្វះខាតនៅឡើយ ព្រោះមានភ័យខ្លាចពីសុវត្ថិភាព ហើយទទួលព័ត៌មានក៏នៅមានការខ្វះខាតដែរ និងបានសំណូមពរឱ្យសង្គមស៊ីវិលជួយបំភ្លឺឱ្យអាជ្ញាធរមូលដ្ឋានកុំ ឱ្យមានការប្រកាន់និន្នាការគណបក្សនយោបាយ។

### 2.1.5. គណបក្សសិទ្ធិមនុស្ស

មិនមានទីស្នាក់ការ និងតំណាងក្នុងខេត្តមណ្ឌលគីរីទេ។

### 2.1.6. គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត

ប្រព័ន្ធបោះឆ្នោតជាសមាមាត្រ ឬ ប្រព័ន្ធឯកត្តនាម សុទ្ធតែល្អទាំងអស់ វាអាស្រ័យទៅលើការកំណត់ពីថ្នាក់លើ ថ្នាក់ខេត្តចាំតែអនុវត្តន៍ប៉ុណ្ណោះ។ ចំពោះការកំណត់កូតាស្ត្រីឱ្យបានចូលរួម ៣០% លោកមានការយល់ស្រប។ ចំពោះបទបញ្ញា នីតិវិធីវាអាចមានភាពស្មុគស្មាញសម្រាប់ប្រជាពរដ្ឋដែលគាត់មានកំរិតយល់ដឹងទាប ប៉ុន្តែសម្រាប់អ្នកមានការយល់ដឹង មិនចោទជាបញ្ហាទេ។

សម្រាប់ស្ថានភាពបច្ចុប្បន្ននេះទម្រង់ ១០១៨ នៅតែចាំបាច់សម្រាប់អ្នកបោះឆ្នោត។ ចំពោះយោបល់ថាគួរមានមន្ត្រីរបស់ គ .ជ.ប ចុះជួយស្មៀននៅពេ លចុះឈ្មោះបោះឆ្នោត គឺវាអាស្រ័យទៅលើថវិកា និងគ.ជ.ប អ្នករៀបចំ។ គួរតែមានការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតាមភូមិ និងឱ្យមេភូមិពង្រឹងការផ្សព្វផ្សាយ បន្ថែមទៀត។ ចំពោះការផ្សព្វផ្សាយ កន្លងមកមានលក្ខណៈល្អប្រសើហើយ។ រីឯការដោះស្រាយបណ្តឹងវា អាស្រ័យទៅតាមច្បាប់ដែលបានកំណត់។ ចំពោះហិរញ្ញវត្ថុគណបក្សនយោបាយវាអាស្រ័យគណបក្សនីមួយៗចង់ផ្សព្វផ្សាយ ឬអត់ ហើយមិនគួរមានការកំណត់ទេ។ ការអប់រំអ្នកបោះឆ្នោតនៅជួបការលំបាក ព្រោះអ្នកតំបន់ដាច់ ស្រយាលភាគច្រើនជាជនជាតិភាគតិច ហើយពួកគាត់មិនចេះអក្សរខ្មែរ។

ចំពោះសេរីភាពក្នុងការបញ្ចេញមតិបានល្អភាគច្រើន នៅកន្លែងខ្លះមានការលាក់លៀមមិនហ៊ានសំដែងមតិ ព្រោះចំណេះដឹងទាប ហើយសេរីភាពប្រមូលផ្តុំបានល្អប្រសើរ ព្រោះមិនដែលមានការហាមឃាត់ និងប្រើអំពើហឹង្សាទេនៅខេត្តមណ្ឌលគីរី។ រីឯសិទ្ធិក្នុងការទទួលព័ត៌មានវិញប្រជាពលរដ្ឋមានសិទ្ធិ ប៉ុន្តែមួយចំនួនខ្វះខាតមធ្យោបាយ។

### 2.1.7. គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត

ប្រព័ន្ធអនុវត្តន៍សព្វថ្ងៃល្អប្រសើរហើយ តែបើមានឯកត្តនាមកាន់តែប្រសើរ។ ការកំណត់កូតាស្ត្រីឱ្យបានច្រើនជាការប្រសើរ។ គួរតែមានការបង្កើតគណៈកម្មការចំរុះពីអង្គការជាតិ និងអន្តរជាតិ ក្នុងការជ្រើសរើស និងត្រួតពិនិត្យសកម្មភាពសមាជិក គ .ជ.ប ប៉ុន្តែមិនចាំបាច់កំណត់អណត្តិទេ។ គួរបន្តប្រើទម្រ ង់ ១០១៨ ព្រោះការចេញអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋមិនទាន់បានគ្រប់ គ្នានៅឡើយ។ បើ គ .ជ.ប អាចចាត់តាំងមន្ត្រី របស់ខ្លួនមកជួយការងាររបស់ស្មៀនក្នុងការចុះឈ្មោះអ្នកបោះឆ្នោតគឺជាការល្អប្រសើរ ហើយគួរតែ មានការចុះឈ្មោះនៅតាមភូមិ។ចំពោះប្រព័ន្ធផ្សព្វផ្សាយ និងការដោះ ស្រាយបណ្តឹងកន្លងមកមានភាពល្អប្រសើរហើយ មិនចាំបាច់ធ្វើការផ្លាស់ប្តូរអ្វីទេ។ គួរតែមានការកំណត់ចំណាយរ បស់គណបក្ស

នយោបាយក្នុងពេលបោះ ឆ្នោត។ សេរីភាពក្នុងការបញ្ចេញមតិ ទទួលព័ត៌មាន និងការប្រមូលផ្តុំកន្លងមកមានលក្ខណៈល្អប្រសើរហើយ។

### 2.1.8. ស្មៀនឃុំ

ប្រព័ន្ធបោះឆ្នោតគួរតែអនុវត្តន៍ដូចរយៈពេលកន្លងមក។ គាំទ្រចំពោះការកំណត់ឱ្យមានស្ត្រីចូលរួមច្រើន។ បើមានលទ្ធភាពក្នុងការបង្កើតឱ្យមានគណៈកម្មការចម្រុះ ក្នុងការជ្រើសរើសសមាជិក គ .ជ.ប ជាការល្អប្រសើរដែរ ហើយសមាជិក គ .ជ.ប គួរតែមានការកំណត់អណត្តិ។ ការចុះឈ្មោះអ្នកបោះឆ្នោតកន្លងមកមានជួបការលំបាកខ្លះដែរដូចជា បញ្ហាទៅបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបន្សល់តាំងពីឆ្នាំ ១៩៩៨ ដែលពេលនោះ គ .ជ.ប បានចាត់តាំងមន្ត្រីខ្លួនបំពេញការងារចុះឈ្មោះនេះ ហើយមួយទៀតទាក់ទងការលុបឈ្មោះអ្នកបោះ ព្រោះជួយការលំបាកក្នុងការស្វែង រកឯកសារយោងដើម្បីលុបឈ្មោះ។ ចំណុចមួយផ្សេងទៀតគឺកា រខុសឈ្មោះដោយប្រជាពលរដ្ឋយកឯកសារពីរផ្សេងគ្នាទៅចុះឈ្មោះ និងទៅបោះឆ្នោត ។ ទម្រង់ ១០១៨ នៅតែចាំបាច់សំរាប់ប្រជាពលរដ្ឋ។ ការប្រតិភូកម្មអំណាចឱ្យស្មៀនក្នុងការចុះឈ្មោះបោះឆ្នោតជាការប្រសើរ ព្រោះស្មៀនគ្រប់គ្រងទិន្នន័យប្រជាពលរដ្ឋក្នុងឃុំបានច្បាស់លាស់ និងជួយសន្សំថវិការបស់ជាតិ។ គួរតែកំណត់ឱ្យមានជំនួយការស្មៀនគ្រប់ឃុំ សង្កាត់ ដើម្បីជួយលើការងារចុះឈ្មោះបោះឆ្នោត ពីព្រោះស្មៀនមានតែម្នាក់ ហើយមានការទទួលខុសត្រូវការងារច្រើន។

ចំពោះការដោះស្រាយបណ្តឹងគួរតែមានបង្កើតគណៈកម្មការចម្រុះដោយឡែកមួយសម្រាប់ធ្វើការដោះស្រាយបណ្តឹង។ នៅថ្ងៃអ នាគតការកំណត់ចំណាយរបស់គណបក្សនយោបាយពេល បោះ ឆ្នោតគួរតែមាន។ ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមានកំរិត ហើយការអប់រំ ផ្សព្វផ្សាយមិនទានបានទូលំទូលាយ។

សេរីភាពក្នុងការបញ្ចេញមតិមិនទាន់បានទូលំទូលាយនៅឡើង កន្លងមកមានតែ គណបក្សឈ្នះឆ្នោតមានឱកាសក្នុងការបញ្ចេញមតិបានច្រើន ជាងគណបក្សឯទៀត។ ការផ្សព្វផ្សាយព័ត៌មានមិនពិត និង បទបរិហាកេរ្តិ៍ សូមកុំឱ្យមានការដាក់ទោសជាប់ពន្ធនាគារ គ្រាន់តែធ្វើការកែតំរូវ និងផាកពិន័យជាប្រាក់បានហើយ។ ប្រជាពលរដ្ឋមានសិទ្ធិក្នុងការទទួលព័ត៌មានប៉ុន្តែខ្វះខាត មធ្យោបាយ។

### 2.1.9. អង្គការក្រៅរដ្ឋាភិបាល

ប្រព័ន្ធបោះឆ្នោតសម្រាប់ប្រទេសកម្ពុជាយើង គួរតែចាប់យកប្រព័ន្ធឯកត្តនាម ឬប្រព័ន្ធចំរុះ។ ទោះជា ប្រព័ន្ធឯកត្តនាមល្អ ទន្ទឹមនិងនេះក៏វាមានគុណវិបត្តិខ្លះដែរ។ ការកំណត់កូតា

ស្ត្រីគឺការល្អ ប៉ុន្តែវាអាស្រ័យ ទៅលើសមត្ថភាព និងថវិកា។ សមាជិក គ .ជ.ប មិនទាន់ មានឯករាជ្យភាពនៅឡើយ បើមើលក្នុង ក្របខ័ណ្ឌច្បាប់បានធានាពីឯករាជ្យភាពរបស់សមាជិក គ .ជ.ប ប៉ុន្តែបុគ្គលខ្លួនឯងនោះមិនឯករាជ្យ។ សមាជិក គ .ជ.ប គួរតែមានការកំណត់អណត្តិ ព្រោះវាសំខាន់ជាងសមាជិករដ្ឋាភិបាលទៅទៀត ប៉ុន្តែសម្រាប់ អ្នកបច្ចេកទេសបំរើការងារនៅ គ .ជ.ប មិនចាំបាច់ កំ ណត់អណត្តិទេ។ នីតីវិធីរបស់គ .ជ.ប នៅមានការ លំបាកសំរាប់ប្រជាពលរដ្ឋនៅឡើយ ជា ពិសេសទៅលើការចេញឯកសារបញ្ជាក់អត្តសញ្ញាណ។ គួរតែបន្តប្រើ ប្រាស់ទម្រង់ ១០១៨ ហើយ ចំពោះការប្រតិភូកម្មអំណាយឱ្យស្មៀនក្នុងការចុះឈ្មោះបោះឆ្នោត គ .ជ.ប ហាក់មិនមានការត្រួតពិនិត្យគ្រប់គ្រាន់ទេ ដូ ចនេះ គ .ជ.ប គួរតែចាត់តាំងមន្ត្រីរបស់ខ្លួន ឱ្យចុះធ្វើការត្រួតពិនិត្យការ ងាររបស់ស្មៀនបន្ថែមទៀត ព្រោះស្មៀននៅមានភាពលំអៀង។ ចំពោះការផ្សព្វផ្សាយកន្លងមកទូរទស្សន៍ជាតិកម្ពុជាបានអនុវត្តន៍ល្អប្រសើរហើយ ប៉ុន្តែចំពោះទូរទស្សន៍ឯកជននៅតែមានការ លំអៀងក្នុងការផ្សព្វផ្សាយ ឱ្យគណបក្សកាន់អំណាច។ ដើម្បីឱ្យមានសមត្ថភាពគ្នាក្នុងការផ្សព្វផ្សាយ គ .ជ.ប ត្រូវតែមានការផាក ពិន័យចំពោះប្រព័ន្ធផ្សព្វផ្សាយទាំងនោះ។ ការបែងចែកនាទីក្នុង ព័ត៌មានសមធម៌មានភាពអយុត្តិធម៌ គួរតែមាន ការបែងចែកឱ្យបានស្មើៗគ្នា។ ចំពោះការដោះស្រាយបណ្តឹង មិនសំខាន់លើការបង្កើតឱ្យមានគណៈកម្មការដោយឡែកទេ វាសំខាន់គឺ គណៈកម្មាធិការ រៀបចំការបោះឆ្នោតគ្រប់លំដាក់ថ្នាក់ឯករាជ្យ។ ចំពោះហិរញ្ញវត្ថុគណបក្សនយោបាយគួរតែមានការកំណត់ការចំណាយរបស់គណបក្សនយោបាយនីមួយៗពេលបោះឆ្នោត។

សេរីភាពក្នុងការបញ្ចេញមតិមិនទាន់បានទូលំទូលាយនៅឡើយ ដោយមានការគៀបសង្កត់ពីគណបក្សកាន់អំណាច។ យើងគួរធ្វើយ៉ាងមេចឱ្យសង្គមស៊ីវិលមានសិទ្ធិ និងអំណាចគ្រប់គ្រាន់ក្នុង បញ្ចេញមតិ ព្រោះវាជាធាតុផ្សំសំខាន់នៃរបបប្រជាធិបតេយ្យ។ អំពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងបទបរិហាកេរ្តិ៍គួរ តែកុំមានការដាក់ពន្ធនាគារ គ្រាន់តែធ្វើការកែតម្រូវ និងផាកពិន័យ ជា ប្រាក់បានហើយ ទន្ទឹមនឹងនេះសារ ព័ត៌មានត្រូវអនុវត្តន៍ទៅតាមក្រមសីលធម៌របស់ខ្លួន និងមិនបំរើឱ្យគណបក្សនយោបាយណាមួយ។ ការទទួលព័ត៌មានស្តីពីគំរោង

អភិវឌ្ឍន៍នានារបស់ រាជរដ្ឋា ភិបាលនៅមានកំរិតទាបនៅឡើយ។ ប្រជាពលរដ្ឋនៅមិនទាន់មានសេរីភាពគ្រប់គ្រាន់ក្នុងការប្រមូលផ្តុំនៅឡើយ ព្រោះតែងតែមានការកំណត់ឱ្យមានការស្នើសុំច្បាប់។

### 2.1.10. ក្រុមប្រឹក្សាខេត្ត/ក្រុង

កម្ពុជាគួរតែអនុវត្តន៍ប្រព័ន្ធសមាមាត្រ ព្រោះវាអាចធានាឱ្យមានសន្តិសុខសង្គម ហើយប្រព័ន្ធឯកត្តនាមទាល់តែអ្នកមានថវិកាច្រើន។ គាំទ្រឱ្យមានការកំណត់ស្ត្រីឱ្យចូលរួមឱ្យបានច្រើនហើយ បញ្ហាសំខាន់វាស្រ័យទៅលើសមត្ថភាពរបស់ស្ត្រី ព្រោះច្បាប់កំណត់ថាបុរស ស្ត្រីមាន

សិទ្ធិស្មើគ្នា។ ចំពោះសមាជិក គ.ជ.ប បើតាមផ្លូវច្បាប់វាមានឯករាជ្យភាពហើយ ប៉ុន្តែទាក់ទងបុគ្គល និង ផ្លូវចិត្តតែងតែមានការលំអៀង។ ការជ្រើសរើសសមាជិក គ .ជ.ប កន្លងមកមានលក្ខណៈល្អប្រសើរហើយ និងមិ នគួរកំណត់អណត្តិទេ។ ការចុះឈ្មោះបោះឆ្នោតកន្លង មកមិនមានបញ្ហាអ្វីគួរឱ្យ កត់សម្គាល់ទេ។ ទម្រង់ ១០១៨ នៅតែចាំបាច់ ហើយការធ្វើប្រតិភូកម្មអំណាចឱ្យស្មៀនធ្វើការចុះឈ្មោះជាដំណើរការល្អ។ ការចុះឈ្មោះរៀងរាល់ឆ្នាំគឺការល្អប្រសើរ។

ការផ្សព្វផ្សាយកន្លងមក គ .ជ.ប មានគ្រប់គ្រង និ ងបែងចែកបានល្អប្រសើរហើយ។ ចំពោះការដោះស្រាយបណ្តឹងគួរតែអនុវត្តន៍តាមនីតិវិធីបច្ចុប្បន្ន និងចំពោះហិរញ្ញវត្ថុគណបក្សនយោបាយ វាអាស្រ័យទៅតាមលទ្ធភាពរបស់គណបក្សនីមួយៗ មិនគួរមានការកំណត់ទេ។

សព្វថ្ងៃនេះកម្ពុជាយើងមានសេរីភាពគ្រប់គ្រាន់ហើយក្នុងការបញ្ចេញមតិ។ ចំពោះការផ្សព្វផ្សាយមិនពិតចំពោះបុគ្គលគួរតែមានការកែសម្រួលឡើង មិនចាំបាច់មានការដាក់គុកទេ ប៉ុន្តែវា អាស្រ័យទៅ កំរិតនៃព័ត៌មានពិតនោះ បើវាមានកំរិតធ្ងន់ធ្ងរត្រូវតែមាន ទោសទណ្ឌឱ្យបានខ្លាំងក្លា។ ប្រជាពលរដ្ឋមានសិទ្ធិ ប៉ុន្តែនៅខ្វះ មធ្យោបាយ ហើយទាក់ទងគំរោង អភិវឌ្ឍន៍កន្លងមក រាជរដ្ឋាភិបាលគ្រាន់តែជូនដំណឹងដល់អ្នកពាក់ព័ន្ធ មិនផ្សព្វផ្សាយទូលំទូលាយទេ។

### 2.1.11. សាធារណៈជន

ចំពោះប្រព័ន្ធបោះឆ្នោតអ្វីក៏បានដែរ រឿងដែលសំខាន់គឺអ្នកជាប់ឆ្នោតទាំងនោះ ជួយដល់សុខទុក្ខប្រជាពលរដ្ឋ វាជារឿងដែលសំខាន់ជាង។ កន្លងមកគណៈកម្មាធិការរៀប ចំការបោះឆ្នោតថ្នាក់ឃុំ និងការិយាល័យ នៅមានភាពលំអៀងជាលក្ខណៈ បុគ្គល ព្រោះសមាសភាពទាំងនោះជ្រើសរើលពីមន្ត្រីរាជការ ដូចនេះគួរតែមានការ ជ្រើសរើសដោយអង្គ ការសង្គមស៊ីវិលវិញទើបល្អប្រសើរជាង។ រយៈកាលកន្លងមកធ្លាប់ជួបបញ្ហាការបាត់ឈ្មោះអ្នកបោះឆ្នោត។ គួរតែមានការចាត់តាំងមន្ត្រីរបស់ គ .ជ.ប ឱ្យធ្វើ ការត្រួតពិនិត្យ ការងាររបស់ស្មៀនក្នុងការចុះឈ្មោះបោះឆ្នោត។ គួរតែមាន ការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតាមភូមិ ព្រោះអ្នកបោះឆ្នោតនៅតំបន់ដាច់ស្រយាលមានការលំបាកក្នុងការទៅពិនិត្យ ឈ្មោះនៅសាលាឃុំ។ គួរតែមានការបង្កើតគណៈកម្មការឯករាជ្យមួយក្នុងការដោះស្រាយវិវាទក្នុងការបោះឆ្នោត។ ហិរញ្ញវត្ថុគណបក្សនយោបាយគួរតែមានការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីប្រភពចំណូលចំណាយរបស់ខ្ល ន។ ប្រជាពលរដ្ឋនៅមានកំរិតយល់ដឹងទាបអំពីការបោះឆ្នោត ដូច្នោះគួរតែ អង្គការក្រៅរដ្ឋាភិបាលជួយជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ប្រជាពលរដ្ឋមានសេរីភាពគ្រប់គ្រាន់ក្នុងការបញ្ចេញមតិ និងទទួលព័ត៌មានក្នុងរយៈពេលកន្លងមក។

ខ.៨ ខេត្តព្រៃវែង

របាយការណ៍នៃកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់ខេត្តព្រៃវែង

1. ពេលវេលានៃសកម្មភាពនៃការជួបប្រជុំពិភាក្សា

| ក្រុមដែលបានជួបពិភាក្សា | ទីកន្លែងពិភាក្សា | កាលបរិច្ឆេទ | រយៈពេល | សមាសភាពក្រុមជួបពិភាក្សា | សមាសភាពខុមហ្វ្រែល |
|---|---|---|---|---|---|
| គណបក្សប្រជាជនកម្ពុជា | ទីស្នាក់ការគណបក្ស | ០៨.០៩.២០១០ | ២ម៉ោង | សមាជិកគណបក្ស ប្រុស:០៣ ស្រី:០ | សួន យុធ្យា គីម សុខុម ឡឹម ជន |
| គណបក្សសមរង្ស៊ី | ទីស្នាក់ការគណបក្ស | ០៦.០៩.២០១០ | ២ម៉ោង | សមាជិកគណបក្ស ប្រុស:០៣ ស្រី:០ | សួន យុធ្យា គីម សុខុម ឡឹម ជន |
| គណបក្សហ្វុនស៊ិនប៉ិច | ទីស្នាក់ការគណបក្ស | ០៦.០៩.២០១០ | ២ម៉ោង | សមាជិកគណបក្ស ប្រុស:០១ ស្រី:០ | សួន យុធ្យា គីម សុខុម ឡឹម ជន |
| គណបក្សជាតិនិយម | ទីស្នាក់ការគណបក្ស | ០៦.០៩.២០១០ | ២ម៉ោង | សមាជិកគណបក្ស ប្រុស:០៣ ស្រី:០ | សួន យុធ្យា គីម សុខុម ឡឹម ជន |
| គណបក្សសិទ្ធិមនុស្ស | ទីស្នាក់ការគណបក្ស | ០៧.០៩.២០១០ | ២ម៉ោង | សមាជិកគណបក្ស ប្រុស:០៣ ស្រី:០ | សួន យុធ្យា គីម សុខុម ឡឹម ជន |
| គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត | ទីស្នាក់ការ គ.ជ.ប ខេត្ត | ០៦.០៩.២០១០ | ២ម៉ោង | ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោត ប្រុស:០១ ស្រី:០ | សួន យុធ្យា គីម សុខុម ឡឹម ជន |
| គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត | ឃុំព្រៃខ្លា | ០៧.០៩.២០១០ | ២ម៉ោង | អតីតសមាជិកគណៈឃុំរៀបចំកាបោះឆ្នោត ប្រុស:០១ ស្រី:០ | សួន យុធ្យា គីម សុខុម ឡឹម ជន |
| ស្មៀនឃុំ | ភូមិបាពាយ | ០៨.០៩.២០១០ | ២ម៉ោង | ស្មៀនឃុំ ប្រុស:០៣ ស្រី:០ | សួន យុធ្យា គីម សុខុម ឡឹម ជន |

| | | | | | |
|---|---|---|---|---|---|
| អង្គការក្រៅរដ្ឋាភិបាល | **ទីស្នាក់ការអង្គការ** | ០៩.០៩.២០១០ | ២ម៉ោង | **ប្រធាន អង្គការសង្គមស៊ីវិល ប្រុស:០៤ ស្រី:០** | សួន យុធ្យា គឹម សុខុម ខឹម ជន |
| ក្រុមប្រឹក្សាខេត្ត/ក្រុង | **ទីស្នាក់ការប្រធាន ក្រុមប្រឹក្សាខេត្ត** | ០៨.០៩.២០១០ | ២ម៉ោង | **ប្រធានក្រុមប្រឹក្សាខេត្ត ប្រុស:០១ ស្រី:០** | សួន យុធ្យា គឹម សុខុម ខឹម ជន |
| សាធារណៈជន | **ភូមិតាកោ ឃុំតាកោ ស្រុក ស្វាយអន្ទរ** | ០៩.០៩.២០១០ | ២ម៉ោង | **ប្រជាពលរដ្ឋ ប្រុស:០៣ ស្រី:០៣** | សួន យុធ្យា គឹម សុខុម ខឹម ជន |

### 2.1. បញ្ហាដែលបានរកឃើញក្នុងអំឡុងពេលពិភាក្សារ

### 2.2. បញ្ហាដែលក្រុមនិមួយៗបានលើកឡើង

#### 2.2.1. គណបក្សប្រជាជនកម្ពុជា

គាំទ្រប្រព័ន្ធបោះឆ្នោតដែលកុំពុងប្រើប្រាស់សព្វថ្ងៃគឺប្រព័ន្ធបោះឆ្នោតសមាមាត្រ ដែលជាប្រព័ន្ធល្អបំផុតសម្រាប់ប្រទេសកម្ពុជាពេលបច្ចុប្បន្ន ហើយគាំទ្រអោយមានសមាសភាពរបស់ស្ត្រីអោយបានច្រើននៅក្នុងឆាកនយោបាយ និងស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។គ.ជ.ប សព្វថ្ងៃនេះធ្វើការបានល្អប្រសើរព្រោះបានរៀបចំការបោះឆ្នោតទាំងសកល និងអសលកបានច្រើនលើករួចមកហើយ។ ការប្រើប្រាស់ទម្រង់១០១៨មិនអាចខ្វះបានព្រោះវាជួយសម្រួលអោយប្រជាពលរដ្ឋដែលបាត់កាតបោះឆ្នោតទៅបោះឆ្នោតបាន។ មានតែស្មៀនឃុំទេដែលជាអ្នកទទួលធ្វើការចុះឈ្មោះដ៍សាកសម្បំផុត ពីព្រោះពួកគាត់ជាអ្នកនៅមូលដ្ឋានជាមួយប្រជាពលរដ្ឋ។ការដោះស្រាយបណ្តឹងកន្លងមកបានធ្វើល្អហើយ ទាំងច្បាប់ទាំងការអនុវត្ត។មិនមានយោបល់ទាក់ទងទៅនឹងបញ្ហាហិរញ្ញវត្ថុនយោបាយ។សេរីភាពទាក់ទងទៅនឹងការបញ្ចេញមតិ ទទួលបានព័ត៌មាន និងប្រមូលផ្តុំបានល្អប្រសើជាងមុន ចំពោះការកំណត់បទល្មើស ការបរិហាកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ទុកអោយសភាជាអ្នកកំណត់ព្រោះសភាជាអ្នកធ្វើច្បាប់។មិនទាន់ហ៊ានសម្រេចអំពីការសហការណ៍នៅពេលធ្វើវេទិការ។

#### 2.2.2. គណបក្សសមរង្ស៊ី

ធ្វើការផ្លាស់ប្តូសមាសភាព គ.ជ.ប ដែលមានសព្វថ្ងៃនេះចេញ។សមាសភាព គ.ជ.ប គួរតែមានតំណាងចេញមកពីគ្រប់គណបក្សនយោបាយដែលមានអសនៈនៅក្នុងរដ្ឋសភា និងអង្គការសង្គមស៊ីវិលហើយសមាសភាពនេះមានពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម។គ.ជ.ប គួរតែ

មានអណត្តិចំនួន៤ឆ្នាំ នៅពេលដែល គ.ជ.ប មានសមាសភាពដូចខាងលើនេះហើយ គ.ជ.ប ជាអ្នកធ្វើកាចុះឈ្មោះបោះឆ្នោតនិងជាអ្នកកាត់ក្តីទៅលើវិវាទបោះឆ្នោត។មិនមានយោបល់អំពីការរៀបចំវេទិការ និងមិនទាន់ហ៊ាននិយាយទុកជាមុនអំពីកិច្ចសហប្រត្តិបត្តការ។

### 2.2.3. គណបក្សហ្វុនស៊ីនប៉ិច

អ្នកជ្រើសរើសសមាសភាព គ.ជ.ប គឺគណៈកម្មការដែលតំណាងគ្រប់គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិល ហើយសមាសភាព គ.ជ.ប គួរតែមានតំណាងអោយគ្រប់គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលផងដែរ ដែលមានសមាសភាបចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោម។ស្ថាប័ននេះត្រូវតែមានចែងក្នុងរដ្ឋធម្មនុញ្ញដើម្បីអោយមានអំណាយខ្លាំង។ មេភូមិ និងស្មៀនឃុំគួរសហការជាមួយនិង គ.ជ.ប ក្នុងការចុះឈ្មោះនិងលប់ឈ្មោះអ្នកបោះឆ្នោត។ មិនមានយោបល់អំពីការរៀបចំវេទិការ និងរីករាយធ្វើកិច្ចសហប្រតិបត្តការ។

### 2.2.4. គណបក្សជាតិនិយម

ចង់អោយប្រើប្រព័ន្ធឯកត្តនាម ព្រោះប្រព័ន្ធនេះអាចធ្វើអោយបុគ្គលដែលទទួលសន្លឹកឆ្នោតដោយផ្ទាល់ពីប្រជាជនទើបអាចបំរើប្រជាជនតាមមូលដ្ឋានបាន។គ.ជ.ប គួរតែមានសមាសភាពតំណាងមកពីគ្រប់គណបក្សនយោបាយដែលមានអសនៈនៅក្នុងសភា និងគណបក្សដែលបានចុះបញ្ជីត្រឹមត្រូវជាមួយក្រសួងមហាផ្ទៃនិងអង្គការសង្គមស៊ីវិល។ហើយសមាសភាពនេះត្រូវតែមានគ្រប់ជាន់ថ្នាក់នៅក្នុងសមាសភាព គ.ជ.ប ហើយត្រូវតែមានអណត្តដូចសភា និងព្រឹទ្ធសភាដែរ។រីឯការចុះឈ្មោះសុំអោយគ.ជ.ប ជាអ្នកធ្វើហើយសហការជាមួយនឹងអង្គការសង្គមស៊ីវិល។ មិនមានយោបល់អំពីការរៀបចំវេទិការ និងរីករាយធ្វើកិច្ចសហប្រតិបត្តការ។

### 2.2.5. គណបក្សសិទ្ធិមនុស្ស

ចង់បានប្រព័ន្ធបោះឆ្នោតចំរុះដែលមានបញ្ជីបេក្ខជនឯករាជ្យដែលធ្វើអោយម្ចាស់ឆ្នោតស្គាល់អ្នកតំណាងរបស់ខ្លួនឯងបានច្បាស់លាស់។ការជ្រើសរើសសមាសភាព គ.ជ.ប គួរតែក្រសួងមហាផ្ទៃធ្វើការសហការជាមួយនឹងអង្គការសង្គមស៊ីវិល រីឯសមាសភាពរបស់ គ.ជ.ប គួរមានតែអង្គការសង្គមស៊ីវិលសុទ្ធសាធដែលយ៉ាងហោចណាស់សមាសភាពនេះគួមាននៅថ្នាក់ជាតិ។ស្ថាប័ន គ.ជ.ប គួរមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ហើយសមាជិកនិមួយៗត្រូវមានកំរិតវប្បធ៌មច្បាស់លាស់ ហើយស្ថាប័ននេះជាអ្នកទទួលចុះឈ្មោះនិងលប់ឈ្មោះអ្នកបោះឆ្នោត។ មិនមានយោបល់អំពីការរៀបចំវេទិការ និងរីករាយធ្វើកិច្ចសហប្រតិបត្តការ។

### 2.2.6. គណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោត

ប្រព័ន្ធបោះឆ្នោតដែលកំពុងប្រើប្រាស់សព្វថ្ងៃនេះល្អប្រសើរហើយសម្រាប់កម្ពុជា។ប្រសិនជាមានបេក្ខជនឯករាជ្យអាចឈរឈ្មោះបោះឆ្នោតបានគឺរឹតតែល្អ។គាំទ្រអោមានកូតាស្ត្រីចំនួន ៣០%នៅក្នុងរដ្ឋសភាជាតិ។ទាក់ទងទៅនឹង គ.ជ.ប មិនមានយោបល់ទុកអោយសភាជាអ្នក

ធ្វើច្បាប់សម្រេចចុះ។ទម្រង់១០១៨នៅតែសំខាន់ធ្វើរហ័សជាងគេពេលបោះឆ្នោត។ការពិនិត្យឈ្មោះជារៀងរាល់ឆ្នាំរបស់ប្រជាពលរដ្ឋជាកាតព្វកិច្ចតាមច្បាប់ដូច្នេះវាមិនមានអ្វីធ្ងន់ធ្ងរទេ។មិនមានយោបល់ទាក់ទងទៅនឹងហិរញ្ញវត្ថុគណបក្សនយោបាយ សេរីភាពក្នុងការបញ្ចេញមតិការទទួលបានព័ត៌មាន និងសេរីភាបក្នុងការប្រមូលផ្តុំគ្នា។ការអប់រំអ្នកបោះឆ្នោតសុំអោយអង្គការសង្គមស៊ីវិលជួយផ្សព្វផ្សាយថែមទៀត។មិនមានយោបល់ទាក់ទងទៅនឹងការធ្វើវេទិការ មិនទាន់ហ៊ាននិយាយជាមុនអំពីការសហការណ៍។

### 2.2.7. គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត

ស្ថាប័ន គ.ជ.ប គួរតែចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញហើយមានអណត្តសម្រាប់សមាជិក គ.ជ.ប។ការលប់បំបាត់ទម្រង់១០១៨ចោលធ្វើអោយមានការបាត់បង់អ្នកទៅបោះឆ្នោតច្រើន ពីព្រោះមានប្រជាពលរដ្ឋជាច្រើនដែលពុំទាន់ទទួលបានអត្តសញ្ញាណប័ណ្ណ។ សូមអោយ គ.ជ.ប ធ្វើការសហការជាមួយនិងស្មៀនឃុំនិងមេភូមិក្នុងការចុះឈ្មោះនិងលប់ឈ្មោះបោះឆ្នោត។បង្កើតអោយមានគណៈកម្មកាចាក់ផ្សាយដើម្បីធានាបានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអោយបានស្មើរៗគ្នា។ការប្រកាសទ្រព្យសម្បត្តិនិងបំណុលរបស់សមាជិកសភា និងរដ្ឋរដ្ឋាភិបាលគួតែអោយប្រជាពលរដ្ឋបានដឹងដែរ។ មិនមានយោបល់អំពីការរៀបចំវេទិការ និងរីករាយធ្វើកិច្ចសហប្រតិបត្តការ។

### 2.2.8. ស្មៀនឃុំ

បើមានសមាសភាពអង្គការសង្គមស៊ីវិលនៅក្នុងសមាសភាព គ.ជ.ប គឺរឹតតែជាការប្រសើរដើម្បីធានាបានអោយស្ថាប័ននេះធ្វើការឯករាជ្យ និងអព្យាក្រិត្យថែមទៀត។ចំណែកឯការចុះឈ្មោះបោះឆ្នោត និងលប់ឈ្មោះវិញមិនអាចមានអ្នកធ្វើកើតក្រៅពី ស្មៀនឃុំ និងមេភូមិបានទេពីព្រោះពួកគាត់ជាមនុស្សដែលរស់នៅតាមមូលដ្ឋាន ដែលជាអ្នកដឹងច្បាស់ជាងគេពីចំនួនប្រជាជននៅតាមមូលដ្ឋានដែរ។ គាំទ្របង្កើតអោយមានគណៈកម្មការចាក់ផ្សាយដែលនៅក្នុងនោះមានសមាសភាពអង្គការសង្គមស៊ីវិលនៅក្នុងនោះដែរ ដើម្បីធានាអោយមានសមភាពសម្រាប់គណបក្សនិមួយៗ។ មិនមានយោបល់អំពីការរៀបចំវេទិការ និងរីករាយធ្វើកិច្ចសហប្រតិបត្តការ។

### 2.2.9. អង្គការក្រៅរដ្ឋាភិបាល

ចង់អោយប្រើប្រព័ន្ធបោះឆ្នោតឯកត្តនាម ពីព្រោះអាចជ្រើសរើសមនុស្សដែលអ្នកបោះឆ្នោតស្រលាញ់ពេញចិត្ត។ ចង់អោយមានអង្គការសង្គមស៊ីវិលនៅក្នុងសមាសភាព គ.ជ.ប តាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម។ ចង់អោយប្រព័ន្ធផ្សព្វផ្សាយទាំងអស់ប្រើប្រាស់គោលការណ៍សមភាពចំពោះគ្រប់គណបក្សទាំងអស់។ អោយមានសមាសភាពអង្គការសង្គមស៊ីវិលមាននៅក្នុងតុលាកាបោះឆ្នោតដែរ។ចំពោះសេរីភាពប្រមូលផ្តុំអាចធ្វើទៅបានតែមានការលំបាក។ គួរតែមិន

ការកំណត់ចំនួនមនុស្សក្នុងចូលរួមធ្វើបាតុកម្ម។ មិនមានយោបល់អំពីការរៀបចំវេទិការ និងរីករាយធ្វើកិច្ចសហប្រតិបត្តការ។

### 2.2.10.ក្រុមប្រឹក្សាខេត្ត/ក្រុង

ប្រព័ន្ធបោះឆ្នោតសមាមាត្រគឺល្អបំផុតសម្រាប់ប្រទេសកម្ពុជាពេលបច្ចុប្បន្ននេះ ហើយក៏យុត្តិធ៌មដែរ។តែបើច្បាប់មានចែងអោយមានបេក្ខជនឯករាជ្យឈរឈ្មោះបោះឆ្នោតទៀតគឺរឹតតែល្អ។គាំទ្រអោយមានការចូលរួមពីស្ត្រីយ៉ាងតិច៣០%។ចំពោះសមាជិករបស់ គ.ជ.ប គឺជាមនុស្សត្រូវតែគោរពច្បាប់ ពេលធ្វើការគោរពតាមច្បាប់គឺមានន័យថា ឯករាជ្យ។តែពិបាករកមនុស្សដែលអាចគោរពច្បាប់អោយបានល្អ ឬមនុស្សអព្យាក្រិត្យណាស់។គួរតែមានការកំណត់ស្តង់ដាសម្ថភាពសម្រាប់មន្ត្រី គ.ជ.ប។គួរតែមានការថែមប្រាក់អោយទៅស្មានឃុំដើម្បីអោយគាត់បំពេញការងារអោយបានល្អ។ ការទៅពិនិត្យឈ្មោះរបស់ប្រជាជនជារៀងរាល់ឆ្នាំគឺជាបន្ទុកដ៏ធ្ងន់ធ្ងររបស់ប្រជាពលរដ្ឋ គួតែរកនូវវិធិផ្សេងពីនេះ។ប្រព័ន្ធផ្សព្វផ្សាយរាល់ថ្ងៃធ្វើបានល្អហើយ។ ការដោះស្រាយបណ្តឹងទាក់ទងទៅនឹងការបោះឆ្នោតធ្វើបានល្អ ហើយមាននីតិវិធីស្រាប់។ ការមានច្បាប់ហិរញ្ញវត្ថុគណបក្សនយោបាយមិនសំខាន់។ទាក់ទងទៅនឹងការបញ្ចេញមតិ ការទទួលបានព័ត៍មាន និងការប្រមូលផ្តុំគ្នាគឺបានល្អហើយ ហើយទៅមុខទៀតនឹងបានល្អប្រសើទៀតជាមិនខាន។រីករាយនឹងសហការណ៍ជាមួយវេទិការពេលបានទទួលលិខិត្តត្រឹមត្រូវសិន។

### 2.2.11. សាធារណៈជន

ចង់បានប្រព័ន្ធបោះឆ្នោតឯកត្តនាមដើម្បីងាយស្រួលបោះឆ្នោតជ្រើសរើសអ្នកពេញចិត្ត។ សុំអោយឈប់ប្រើប្រាស់នូវទម្រង់១០១៨ទៀតដោយប្រើប្រាស់អត្តសញ្ញាណប័ណ្ណជំនួសវិញ។ គ.ជ.ប គួរតែធ្វើការចុះឈ្មោះបោះឆ្នោតវិញពីព្រោះស្មៀនឃុំ និងមេភូមិតែងតែបង្ករការលំបាកដល់ប្រជាពលរដ្ឋដែលទៅចុះឈ្មោះ ដែលធ្វើអោយប្រជាពលរដ្ឋលែងចង់ទៅឈ្មោះទៀត។បង្កើតអោយមានគណៈកម្មការចាក់ផ្សាយមួយដើម្បីអោយមានសមភាពក្នុងការចាក់ផ្សាយនូវរាល់សកម្មភាពរបស់គណបក្សនិមួយៗដើម្បីអោយប្រជាពលរដ្ឋបានតាមដានគ្រប់សកម្មភាពនៃគណបក្សនិមួយៗ។ការអប់រំអ្នកបោះឆ្នោតនៅមានកំរិតសូមអោយអោយអង្គការសង្គមស៊ីវិលជួយបន្ថែមទៀតផង។

Funded By

UNDP


## ខុមហ្វ្រែល

ទីស្នាក់ការកណ្តាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 885 745
E-mail: comfrel@online.com.kh Website: http://www.comfrel.org